ក្រសួងអប់រំ យុវជន និងកីឡា

# ឯកសារណែនាំប្រតិបត្តិ
# ស្តីពី
# មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា

(សម្រាប់គណៈគ្រប់គ្រងសាលារៀន និងគ្រូប្រឹក្សាតាមសាលារៀន)




នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

ឆ្នាំ២០២១

# បុព្វកថា

កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា គឺជាទស្សនាទានថ្មីមួយដែលទើបត្រូវបានដាក់ឱ្យអនុវត្ត នៅតាមគ្រឹះស្ថានមធ្យមសិក្សាគោលដៅមួយចំនួន ក្នុងព្រះរាជាណាចក្រកម្ពុជាចាប់ពីឆ្នាំ២០១៥ រហូតមកទល់បច្ចុប្បន្ន។ ជាសារតៈដើមដែលកំពុងត្រូវបានអនុវត្តនៅតាមបណ្តាប្រទេសអភិវឌ្ឍន៍លើសកលលោក កម្មវិធីនេះត្រូវបានដាក់ឱ្យអនុវត្តយ៉ាងទូលំទូលាយចាប់ពីកម្រិតមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា ដើម្បីផ្តល់ការគាំទ្រដល់សិស្ស និស្សិតឱ្យសម្រេចបាននូវភាពជោគជ័យក្នុងការសិក្សា និងអាជីពផ្ទាល់ខ្លួន។

ផ្អែកលើស្ថានភាពជាក់ស្តែង ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យអនុវត្តកម្មវិធីនេះនៅកម្រិតមធ្យមសិក្សាជាជំហានដំបូង ដែលជាផ្នែកមួយនៃប្រព័ន្ធគាំទ្របន្ទាន់ ក្នុងការជួយកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស និងជួយសិស្សឱ្យមានមូលដ្ឋានក្នុងការរៀបចំផែនការសិក្សា និងអាជីពមុខរបររបស់ខ្លួននាថ្ងៃអនាគត បានសមស្របតាមចំណង់ចំណូលចិត្ត និងឧបនិស្ស័យ ព្រមទាំងផ្សារភ្ជាប់ទំនាក់ទំនងរវាងការអប់រំមធ្យមសិក្សា និងក្រោយមធ្យមសិក្សា។ ការណ៍នេះ គឺជាការអនុវត្តអន្តរាគមន៍ផ្នែកបច្ចេកទេស ដោយផ្ទាល់ក្នុងការកាត់បន្ថយបញ្ហាគម្លាតជំនាញ និងភាពមិនស៊ីគ្នារវាងការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្មក្នុងទីផ្សារការងារនៅកម្ពុជា ឆ្លើយតបទៅនឹងគោលនយោបាយមុខរបរ និងការងារ (២០១៥-២០២៥) និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (២០១៥-២០២៥) របស់រាជរដ្ឋាភិបាលកម្ពុជា។

ឯកសារណែនាំប្រតិបត្តិស្តីពី **«មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា សម្រាប់គណៈគ្រប់គ្រងសាលារៀន និងគ្រូប្រឹក្សាតាមសាលារៀន»** ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់នូវផែនទីបង្ហាញផ្លូវដល់គណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន គ្រូបង្រៀនតាមមុខវិជ្ជា សិស្សានុសិស្ស មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងសហគមន៍មូលដ្ឋាន អំពីទិដ្ឋភាពទូទៅ យន្តការការងារ ឧបករណ៍គាំទ្រក្របខណ្ឌបច្ចេកទេស លំហូរសកម្មភាព វិធីសាស្ត្រប្រតិបត្តិ និងដៃគូសហការពាក់ព័ន្ធនានា ក្នុងដំណើរការអនុវត្ត នៅតាមសាលារៀន ដើម្បីឱ្យកម្មវិធីនេះទទួលបានជោគជ័យជាវិជ្ជមាន។

ក្រសួងអប់រំ យុវជន និងកីឡា សូមកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មន្ត្រីជំនាញ នៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ និងស្ថាប័នដៃគូពាក់ព័ន្ធ ដែលបានខិតខំ និងរួមចំណែកកសាងឯកសារ ដ៏មានសារៈសំខាន់នេះ។ ក្រសួងសង្ឃឹម និងជឿជាក់ថាអង្គភាពពាក់ព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ពិសេស កម្រិតសាលារៀន នឹងចូលរួមសហការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដោយភាពទន់ភ្លន់ បត់បែន និងស្មារតីទទួលខុសត្រូវខ្ពស់ តាមតួនាទីភារកិច្ចរៀងៗខ្លួន។

ថ្ងៃ សុក្រ ១៤កើត ខែ ទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា

**បុព្វកថា**......ii
**មាតិកា**......iii
**១. សេចក្តីផ្តើម**...... ១
**២. មូលដ្ឋានទូទៅនៃមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា**...... ២
២.១ និយមន័យ...... ២
២.២ គោលដៅ...... ២
២.២.១ ការអភិវឌ្ឍផ្នែកអប់រំ...... ២
២.២.២ ការអភិវឌ្ឍផ្នែកអាជីព...... ៣
២.២.៣ ការអភិវឌ្ឍផ្នែកបុគ្គលិកលក្ខណៈ...... ៣
២.៣ ការផ្សារភ្ជាប់រវាងបញ្ហាសមភាពយេនឌ័រ និងបរិយាបន្នសង្គម...... ៣
២.៤ ទ្រឹស្តីនៃការផ្លាស់ប្តូរ...... ៤
២.៥ ការញែកមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ចេញពី «ការប្រឹក្សាផ្លូវចិត្ត»...... ៥
២.៦ អត្ថប្រយោជន៍កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា...... ៥
២.៦.១ អត្ថប្រយោជន៍សម្រាប់សិស្ស...... ៥
២.៦.២ អត្ថប្រយោជន៍សម្រាប់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស...... ៦
២.៦.៣ អត្ថប្រយោជន៍សម្រាប់គ្រូមុខវិជ្ជា និងគ្រូបន្ទុកថ្នាក់...... ៦
២.៦.៤ អត្ថប្រយោជន៍សម្រាប់គណៈគ្រប់គ្រង និងសាលារៀន...... ៦
២.៦.៥ អត្ថប្រយោជន៍សម្រាប់សហគ្រាសអាជីវកម្មក្នុងមូលដ្ឋាន...... ៧
២.៦.៦ អត្ថប្រយោជន៍សម្រាប់ថ្នាក់ជាតិ...... ៧
២.៧ សមាសភាពចូលរួម ដើម្បីភាពជោគជ័យនៃការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា...... ៨
**៣. គោលការណ៍មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា**...... ៩
៣.១ គោលការណ៍មូលដ្ឋាន...... ៩
៣.២ ការបណ្តុះបណ្តាលគ្រូប្រឹក្សាតាមសាលារៀន...... ៩
៣.២.១ ការបណ្តុះបណ្តាលបន្ត (In-service Training)...... ១០
៣.២.២ ការបណ្តុះបណ្តាលដំបូង (Pre-service Training)...... ១០
៣.៣ តួនាទីភារកិច្ចគ្រូប្រឹក្សាតាមសាលារៀន...... ១០
៣.៣.១ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់...... ១១
៣.៣.២ សេវាប្រឹក្សាទល់មុខ...... ១២
៣.៣.៣ សេវាការងារបណ្តាញ...... ១២
៣.៤ តួនាទីភារកិច្ចគ្រូមុខវិជ្ជា និងគ្រូបន្ទុកថ្នាក់...... ១២

៣.៥ តួនាទីភារកិច្ចគណៈគ្រប់គ្រងសាលារៀន ..................... ១៣
៣.៦ តួនាទីភារកិច្ចគណៈកម្មការគ្រប់គ្រងសាលារៀន ..................... 14
៣.៧ តួនាទីភារកិច្ចអង្គភាពថ្នាក់ក្រោមជាតិ ..................... ១៤
៣.៨ តួនាទីភារកិច្ចអង្គភាពថ្នាក់ជាតិ (នាយកដ្ឋានជំនាញ) ..................... 14
**៤. ឧបករណ៍ និងការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា** ..................... ១៥
៤.១ ឧបករណ៍សម្រាប់សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់ ..................... ១៥
៤.១.១ ឧបករណ៍សម្រាប់មធ្យមសិក្សាបឋមភូមិ ..................... ១៥
៤.១.២ ឧបករណ៍សម្រាប់មធ្យមសិក្សាទុតិយភូមិ ..................... ១៦
៤.២ ការអនុវត្តកម្មវិធីសិក្សាសម្រាប់សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់ ..................... ១៦
**៥. ដំណើរការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា** ..................... ១៧
៥.១ ការរៀបចំផែនការ និងថវិកាគាំទ្រ ..................... ១៧
៥.២ ការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ..................... ១៨
៥.២.២ ការតម្រង់ទិសសិស្សក្នុងដំណាក់កាលឆ្លងភូមិសិក្សា ..................... ១៨
៥.២.៣ ការតម្រង់ទិសសិស្សមធ្យមសិក្សាទុតិយភូមិ ..................... ១៩
៥.២.៤ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ ..................... ២០
៥.២.៥ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ ..................... ២០
៥.២.៦ សេវាផ្តល់ប្រឹក្សាទល់មុខ ..................... ២១
៥.២.៧ ការប្រើប្រាស់កម្មវិធីត្រីវិស័យ ..................... ២២
៥.២.៨ កម្មវិធីជំនួបមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស ..................... ២២
៥.៣ សកម្មភាពពាក់ព័ន្ធនឹងកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ..................... ២៣
៥.៣.១ ការគាំទ្រវិវាទវិយាបថវិជ្ជមានរបស់សិស្ស (ទិវាគ្រូបង្រៀន...) ..................... ២៣
៥.៣.២ ការបង្កើតក្លឹបសិក្សា ..................... ២៣
៥.៣.៣ ការបង្កើតការងារគម្រោងរបស់សិស្ស ..................... ២៤
៥.៣.៤ ការប្រកួតប្រជែងនវានុវត្តន៍ ..................... ២៥
៥.៣.៥ ការប្រកួតប្រជែងសហគ្រិនភាព ..................... ២៥
៥.៣.៦ ការតាំងពិព័រណ៍សមិទ្ធផលស្នាដៃសិស្ស ..................... ២៦
**៦. ការបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍ក្នុងមូលដ្ឋាន** ..................... ២៧
៦.១ គោលបំណង ..................... ២៧
៦.២ ការបង្កើតបណ្តាញជាមួយសហគមន៍ក្នុងមូលដ្ឋាន ..................... ២៧
៦.៣ យន្តការនៃការបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍ក្នុងមូលដ្ឋាន ..................... 28
៦.៣.១ កម្មវិធីជំនួបជាមួយសហគមន៍ក្នុងមូលដ្ឋាន ..................... ២៨

៦.៣.២ វេទិកាចែករំលែកបទពិសោធដោយវាគ្មិន ....................................................... ២៨
៦.៣.៣ វេទិកាជជែកពិភាក្សា (វាគ្មិនច្រើន) ....................................................... ២៩
៦.៣.៤ ទស្សនកិច្ចសិក្សា ....................................................... 30
៦.៣.៥ ការសង្កេតការងារ ....................................................... ៣០
៦.៣.៦ ការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ការងារខ្នាតតូច ....................................................... ៣១
**៧. ការពិនិត្យតាមដាន និងវាយតម្លៃ** ....................................................... ៣២
**៨. សេចក្តីសន្និដ្ឋាន** ....................................................... ៣២
**ឧបសម្ព័ន្ធ១** គំរូផែនការសកម្មភាព និងថវិកាគាំទ្រ ....................................................... ៣៣
**ឧបសម្ព័ន្ធ២** គំរូគម្រោងចំណាយថវិកាលម្អិតតាមសកម្មភាពនីមួយៗ ....................................................... ៣៥
**ឧបសម្ព័ន្ធ៣** របាយការណ៍ប្រចាំសប្តាហ៍នៃការអនុវត្តសេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់ ....................................................... ៣៩
**ឧបសម្ព័ន្ធ៤** ដំណាក់កាលនៃការផ្តល់ប្រឹក្សាទល់មុខ ....................................................... ៤០
**ឧបសម្ព័ន្ធ៥** គំរូកំណត់ត្រាអំពីការផ្តល់សេវាប្រឹក្សាទល់មុខ ....................................................... ៤៣
**ឧបសម្ព័ន្ធ៦** ការអនុវត្តកម្មវិធីត្រីវិស័យ ....................................................... ៤៥
**ឧបសម្ព័ន្ធ៧** គំរូលិខិតអញ្ជើញជំនួបមាតាបិតាសិស្ស ....................................................... ៤៨
**ឧបសម្ព័ន្ធ៨** គំរូរបាយការណ៍សេវាការងារបណ្តាញ ....................................................... 51
**ឧបសម្ព័ន្ធ៩** គំរូលិខិតអញ្ជើញ ជំនួបជាមួយសហគមន៍ក្នុងមូលដ្ឋាន ....................................................... ៥៣
**ឧបសម្ព័ន្ធ១០** គំរូកិច្ចព្រមព្រៀងសិស្សចុះទស្សនកិច្ចសិក្សា ....................................................... ៥៦
**ឧបសម្ព័ន្ធ១១** គំរូកិច្ចសន្យា សង្កេតការងារ ....................................................... ៦០
**ឧបសម្ព័ន្ធ១២** គំរូរបាយការណ៍ប្រចាំខែ ....................................................... ៦៤
**ឧបសម្ព័ន្ធ១៣** គំរូរបាយការណ៍ស្ថិតិសិស្សដើមឆ្នាំ និងចុងឆ្នាំ ....................................................... ៦៧
**ឧបសម្ព័ន្ធ១៤** ផែនទីបង្ហាញផ្លូវដៃគូបណ្តាញរបស់គ្រូប្រឹក្សាតាមសាលារៀន ....................................................... ៧១
**ឧបសម្ព័ន្ធ១៥** បញ្ជីចំណងជើងមេរៀនកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន ....................................................... ៧៥
**ឧបសម្ព័ន្ធ១៦** ការពិពណ៌នាអំពីបំណិនសតវត្សរ៍២១ ....................................................... ៧៨
**ឯកសារយោង** ....................................................... ៧៩

# ១. សេចក្តីផ្តើម

ឆ្លើយតបនឹងបរិបទសាកលភាវូបនីយកម្ម និងចរន្តនៃបដិវត្តឧស្សាហកម្ម ៤.០ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងដាក់ចេញនូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសំខាន់ៗក្នុងកម្រិតថ្នាក់ជាតិ និងក្នុងកម្រិតបច្ចេកទេសតាមរយៈក្រសួង ស្ថាប័ន អង្គភាពជាសេនាធិការនានា សំដៅរុញច្រាននាវាកម្ពុជាឱ្យឈានឆ្ពោះទៅសម្រេចសេចក្តីប្រាថ្នា ក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និងទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ (SPP, 2016-2025)។ ដើម្បីសម្រេចចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដូចមានចែងក្នុង ចតុកោណទី១ ពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស ស្ថិតក្នុងមុំទី១ អាទិភាពទី៤ បានផ្តោតសំខាន់លើការធ្វើបច្ចុប្បន្នភាព និងការជំរុញការអនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេស នៅមធ្យមសិក្សាទុតិយភូមិ សំដៅបង្កើនការតម្រង់ទិសការសិក្សាទៅកាន់អាជីព ព្រមទាំងលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ជាពិសេសតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP)។

ដើម្បីឆ្លើយតបទៅនឹងក្របខណ្ឌយុទ្ធសាស្ត្រជាតិខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយ ដើម្បីគាំទ្រគោលដៅអភិវឌ្ឍប្រកបដោយចីរភាព «**ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា**»។ ទន្ទឹមនេះផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ បានដាក់ចេញនូវយុទ្ធសាស្ត្រក្នុងការពង្រឹងការសិក្សាឆ្ពោះទៅរកអាជីព តាមរយៈការបង្កើតឡើងនូវកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅតាមគ្រឹះស្ថានមធ្យមសិក្សា ដោយរំលេចចេញនូវសកម្មភាពពាក់ព័ន្ធជាអាទិ៍ ការរៀបចំវេទិកាតម្រង់ទិសអំពីអាជីព មុខរបរ និងការសិក្សាជំនាញ ការរៀបចំពិព័រណ៍តម្រង់ទិសវិជ្ជាជីវៈ កម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន និងកម្មវិធីអប់រំសហគ្រិនភាព ជាដើម។

កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា គឺជាចង្កោមកម្មវិធីមួយដែលរួមប្រមូលផ្តុំទៅដោយសកម្មភាពស្នូលជាច្រើន សំដៅផ្តល់ការគាំទ្រជាវិជ្ជមានដល់សិស្សានុសិស្សឱ្យមានគុណសម្បទាគ្រប់គ្រាន់ក្នុងការក្លាយខ្លួនជាពលរដ្ឋពេញលេញនៃសង្គមជាតិ ជាពិសេសគឺការផ្តល់ឱ្យពួកគេនូវមូលដ្ឋានរឹងមាំ ដើម្បីធ្វើសេចក្តីសម្រេចចិត្តផ្ទាល់ខ្លួនក្នុងការរៀបចំផែនការជីវិត ជម្រើសនៃការអប់រំបន្ត និងជម្រើសអាជីពសក្តិសម។ តាមរយៈការដឹកនាំ និងអនុវត្តសកម្មភាពមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាដែលមានកំណត់នៅក្នុងឯកសារណែនាំនេះ លទ្ធផលសិក្សារបស់សិស្ស បញ្ហាសុខុមាលភាពសង្គម ការឆ្លងភូមិសិក្សាប្រកបដោយសុវត្ថិភាព ការទប់ស្កាត់អត្រាសិស្សបោះបង់នៅតាមសាលារៀន សមភាពក្នុងការអប់រំ និងបញ្ហាយេនឌ័រ នឹងត្រូវបានជ្រោមជ្រែងលើកកម្ពស់ ក្រោមការសម្របសម្រួលរបស់គ្រូប្រឹក្សាតាមសាលារៀន។

ក្នុងការអនុវត្តជាក់ស្តែង ការរៀបចំសកម្មភាពស្នូលមួយចំនួននៃកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា គឺជាតួនាទីទទួលខុសត្រូវរបស់គ្រូប្រឹក្សាតាមសាលារៀន ខណៈសកម្មភាពមួយចំនួនទៀត អាចនឹងរៀបចំទៅបានប្រកបដោយប្រសិទ្ធភាព គឺអាស្រ័យលើការចូលរួមចំណែកពីភាគីពាក់ព័ន្ធសំខាន់ៗជាអាទិ៍ គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំក្នុងអង្គភាពជាមួយគ្នា មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស សហគមន៍ និងភាគីពាក់ព័ន្ធនានា។

# ២. មូលដ្ឋានទូទៅនៃមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា

## ២.១ និយមន័យ

ផ្អែកលើនិយមន័យរបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (OEDC) កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា ត្រូវបានទទួលស្គាល់ជាសកល រួមទាំងប្រទេសដែលមានចំណូលទាប ចំណូលមធ្យម និងចំណូលខ្ពស់ ដូចខាងក្រោម៖

*មគ្គុទ្ទេសក៍អាជីព សំដៅលើសេវាកម្មមួយដែលជួយមនុស្សគ្រប់វ័យ និងគ្រប់ដំណាក់កាលលូតលាស់ក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ក្នុងការបង្កើតជម្រើសនៃការអប់រំ ការបណ្ដុះបណ្ដាលជំនាញ និងមុខរបរ ដើម្បីឈានទៅដឹកនាំគោលដៅអាជីពមួយជាក់លាក់។ តាមរយៈកម្មវិធីនេះ មនុស្សគ្រប់រូបនឹងអាចឆ្លុះបញ្ចាំងពីមហិច្ឆតា ចំណូលចិត្ត បុគ្គលិកលក្ខណៈ និងសមត្ថភាពរបស់ពួកគេ។ បន្ថែមពីនេះ ពួកគេនឹងអាចយល់ដឹងអំពីព័ត៌មានទីផ្សារការងារ ប្រព័ន្ធអប់រំ និងផ្សារភ្ជាប់ទិដ្ឋភាពទាំងនេះទៅនឹងស្ថានភាពផ្ទាល់ខ្លួនបានយ៉ាងល្អ។*

មគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា ក៏អាចនិយាយមួយបែបទៀតបានថា ជាកម្មវិធីគាំទ្រដល់ការអនុវត្តនូវអន្តរសកម្មភាព និងតម្រង់ទិសគោលដៅសិស្សានុសិស្ស ព្រមទាំងជំរុញឱ្យមានការរីកចម្រើន និងការអភិវឌ្ឍផ្ទាល់ខ្លួន។ មគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា ចូលរួមលើកកម្ពស់សមធម៌ សមភាព ទប់ស្កាត់អត្រាបោះបង់ការសិក្សារបស់សិស្សានុសិស្ស លើកកម្ពស់ការអភិវឌ្ឍជំនាញ ការស្គាល់ខ្លួនឯង ការស្វែងយល់ពីពិភពការងារ ការរៀបចំខ្លួនចាប់យកជម្រើសនៃការសិក្សា ការចូលទៅក្នុងពិភពការងារប្រកបដោយប្រសិទ្ធភាព ផលិតភាព និងសុខដុមនីយកម្មវិជ្ជាជីវៈ។

## ២.២ គោលដៅ

កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា ត្រូវបានរៀបចំឡើងដើម្បីដាក់ឱ្យអនុវត្តនៅកម្រិតសាលារៀនតាមរយៈគ្រូប្រឹក្សាតាមសាលារៀន ដោយផ្អែកលើគោលដៅធំៗចំនួន ៣ មានជាអាទិ៍៖ **ការអភិវឌ្ឍផ្នែកអប់រំ ការអភិវឌ្ឍផ្នែកអាជីព** និង**ការអភិវឌ្ឍផ្នែកបុគ្គលិកលក្ខណៈ** ដើម្បីពួកគេអាចធ្វើសមាហរណកម្មខ្លួនទៅ ក្នុងស្ថានភាពជម្រើសនៃការអប់រំបន្ត និងអាជីពមុខរបរ ប្រកបដោយទំនុកចិត្ត ការប្ដេជ្ញាចិត្ត ជំនឿ គុណតម្លៃ និងគុណធម៌ក្នុងជីវិត។

### ២.២.១ ការអភិវឌ្ឍផ្នែកអប់រំ

តាមរយៈកម្មវិធីនេះ សិស្សនឹងទទួលបាននូវ៖




- ឥរិយាបថវិជ្ជមាន ចំណេះដឹង និងជំនាញ ដែលជាកត្តារួមចំណែកដល់ការជំរុញឱ្យការសិក្សា នៅសាលារៀនកាន់តែមានប្រសិទ្ធភាព និងមានស្មារតីស្រឡាញ់ការសិក្សាពេញមួយជីវិត
- ការបញ្ចប់ការសិក្សាតាមកម្រិតថ្នាក់នីមួយៗប្រកបដោយសុវត្ថិភាព ផ្សារភ្ជាប់ជាមួយនឹងការត្រៀមលក្ខណៈសម្បត្តិគ្រប់ជ្រុងជ្រោយ

ក្នុងការបន្តចាប់យកជម្រើសនៃការអប់រំបន្តនៅឆ្នាំសិក្សាបន្ទាប់ និងមុខជំនាញជាក់លាក់នៅឧត្តមសិក្សា ឬគ្រឹះស្ថានអប់រំបច្ចេកទេសវិជ្ជាជីវៈ
- ការយល់ដឹងអំពីទំនាក់ទំនងរវាងការសិក្សា ទៅនឹងពិភពការងារ ជីវភាពរស់នៅក្នុងក្រុមគ្រួសារ និងក្នុងសហគមន៍។

### ២.២.២ ការអភិវឌ្ឍផ្នែកអាជីព

តាមរយៈកម្មវិធីនេះ សិស្សនឹងទទួលបាននូវៈ




- ជំនាញក្នុងការសិក្សាស្រាវជ្រាវ អំពីទំនាក់ទំនងរវាងពិភពការងារ និងចំណេះដឹងផ្ទាល់ខ្លួន ដើម្បីកំណត់នូវជម្រើសអាជីពសក្តិសម
- មូលដ្ឋានក្នុងការរៀបចំខ្លួនឆ្ពោះទៅរកភាពជោគជ័យ និងការពេញចិត្តក្នុងអាជីពជាក់លាក់
- ការយល់ដឹងអំពីទំនាក់ទំនងរវាងគុណសម្បត្តិផ្ទាល់ខ្លួន បុគ្គលិកលក្ខណៈ ការអប់រំ និងបណ្តុះបណ្តាល ទៅនឹងពិភពការងារច្បាស់លាស់។

### ២.២.៣ ការអភិវឌ្ឍផ្នែកបុគ្គលិកលក្ខណៈ

តាមរយៈកម្មវិធីនេះ សិស្សនឹងទទួលបាននូវៈ




- ឥរិយាបថវិជ្ជមាន ចំណេះដឹងមូលដ្ឋានបំណិនសតវត្សរ៍២១ និងជំនាញក្នុងការទំនាក់ទំនង ដើម្បីជួយខ្លួនឯងក្នុងការស្វែងយល់អំពីគុណតម្លៃនៃជីវិត គោរពគ្នាទៅវិញទៅមក រស់នៅក្នុងភាពថ្លៃថ្នូរ
- មូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការកំណត់គោលដៅ និងការរៀបចំផែនការសកម្មភាពគាំទ្រនានា ដើម្បីឱ្យសម្រេចគោលដៅ
- យល់ដឹងអំពីការរស់នៅ ការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងសុខដុមនីយកម្មវិជ្ជាជីវៈ។

## ២.៣ ការផ្សារភ្ជាប់រវាងបញ្ហាសមភាពយេនឌ័រ និងបរិយាបន្នសង្គម

ជាទូទៅ នៅពេលដែលការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា មានដំណើរការទៅដោយរលូន វាអាចជះឥទ្ធិពលជាវិជ្ជមានចំពោះបញ្ហាសមភាពយេនឌ័រ និងបរិយាបន្នសង្គម កាន់តែទូលំទូលាយ។ កម្មវិធីនេះ ផ្តល់លទ្ធភាពឱ្យសិស្សានុសិស្សទទួលបានបំណិនសិក្សារឹងមាំជាងមុន ស្គាល់ខ្លួនឯងច្បាស់ (ទស្សនាទានអំពីបំណិន និងសមត្ថភាពរបស់ខ្លួន និងវិធីប្រើចំណុចទាំងនេះដើម្បីប្រែក្លាយទៅជាឱកាសវិជ្ជមាន និងជម្រើសកាន់តែប្រសើរសម្រាប់ជីវិត) យល់ដឹងបានកាន់តែទូលំទូលាយអំពីបំណិនគាំទ្រក្នុងការបំពេញ

ការងារ ជំនាញទន់ សក្តានុពលនៃការប្រកួតប្រជែងក្នុងទីផ្សារការងារក្នុងមូលដ្ឋាន និងនៅតាមក្រុមហ៊ុនសហគ្រាសនានា។ បន្ថែមលើនេះ កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នឹងផ្តល់ជាប្រយោជន៍ដល់សិស្សដែលជួបការលំបាក សិស្សស្រី សិស្សមកពីគ្រួសារមានជីវភាពខ្វះខាត សិស្សមកពីក្រុមជនជាតិដើមភាគតិច។ល។ ដូចខាងក្រោម៖

- លើកទឹកចិត្តសិស្សស្រីឱ្យមានបំណងចង់បំពេញការងារក្នុងវិស័យផ្សេងៗដូចបុរសដែរ ដែលការងារទាំងនោះមិនមែនជាប្រភេទការងារប្រពៃណី តាមរយៈយន្តការនៃការផ្តល់ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ
- លើកទឹកចិត្តសិស្សប្រុសឱ្យបន្តការសិក្សាចំណេះទូទៅរហូតបញ្ចប់ថ្នាក់វិទ្យាល័យ ឬការអប់រំបច្ចេកទេសនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស និងបន្តការសិក្សាជំនាញកម្រិតខ្ពស់ជាងនេះទៀតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ឬគ្រឹ◌ះស្ថានឧត្តមសិក្សា
- បណ្តុះចំណាប់អារម្មណ៍ការងារ ដើម្បីជំរុញឱ្យសិស្សស្រី និងសិស្សប្រុស អាចមើលឃើញឱកាសថ្មីៗ តាមរយៈការចូលរួមកម្មវិធីទស្សនកិច្ចសិក្សានៅតាមស្ថាប័នការងារជាក់ស្តែង ឬការចូលរួមព្រឹត្តិការណ៍តាំងពិព័រណ៍ការងារក្នុងកម្រិតមូលដ្ឋាន ឬកម្រិតថ្នាក់ជាតិជាដើម
- ទាំងសិស្សស្រី និងសិស្សប្រុស អាចទទួលបានគំរូពីសហគ្រិន អាជីវករ និងធនាគារិក ដែលជាស្ត្រី ឬបុរសជោគជ័យ តាមរយៈការអញ្ជើញពួកគាត់មកធ្វើជាវាគ្មិនចែករំលែកបទពិសោធល្អៗនៅសាលារៀន។

## ២.៤ ទ្រឹស្តីនៃការផ្លាស់ប្តូរ

ជាការពិតណាស់ តាមរយៈកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា សិស្សនឹងទទួលបានជាស្វ័យប្រវត្តិអំពីមូលដ្ឋាននៃការស្គាល់ខ្លួនឯង បុគ្គលិកលក្ខណៈ ចំណុចខ្លាំង ចំណុចខ្សោយ ព័ត៌មានទីផ្សារការងារ ព័ត៌មានពាក់ព័ន្ធនឹងតម្រូវការជំនាញក្នុងការបំពេញការងារ...។ បន្ថែមលើនេះ តាមរយៈអន្តរសកម្មភាពនៅក្នុងកិច្ចដំណើរការសកម្មភាពមួយចំនួនដែលមាននៅក្នុងកម្មវិធីនេះ សិស្សក៏នឹងទទួលបានផងដែរនូវមូលដ្ឋានក្នុងការទំនាក់ទំនងដោយផ្ទាល់ជាមួយអាជីវកម្ម ឬសហគ្រិនក្នុងមូលដ្ឋាន ដើម្បីការពង្រីកវិសាលភាពនៃការយល់ដឹងរបស់ខ្លួនទៅនឹងពិភពការងារជាក់ស្តែង។

ដ្យាក្រាមខាងក្រោមនេះ បង្ហាញនូវរូបភាពដ៏សាមញ្ញមួយអំពីរបៀបដែលមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ត្រូវបានរំពឹងថានឹងដំណើរការប្រកបដោយប្រសិទ្ធភាព។ ប្រសិនបើសិស្សស្គាល់ខ្លួនឯងច្បាស់ ទទួលព័ត៌មានគ្រប់ជ្រុងជ្រោយ មានការគាំទ្រពេញលេញពីក្រុមគ្រួសារ និងមានជំនាញគ្រប់គ្រាន់ ពួកគេនឹងអាចដឹកនាំជីវិតផ្ទាល់ខ្លួនលើផ្លូវវិជ្ជមាន ជ្រើសរើសការសិក្សា និងអាជីពបានសមស្របទៅនឹងស្ថានភាពផ្ទាល់ខ្លួន។

**ការស្គាល់ខ្លួនឯង៖** សិស្សយល់ពីចំណង់ចំណូលចិត្ត បុគ្គលិកលក្ខណៈ ទេពកោសល្យផ្ទាល់ខ្លួន ចំណុចខ្លាំង ចំណុចខ្សោយ សមត្ថភាព និងគោលដៅអនាគត។

**ព័ត៌មាន៖** សិស្សទទួលព័ត៌មានពីប្រភពច្បាស់ លាស់ មានបច្ចុប្បន្នភាព ដែលពាក់ព័ន្ធទៅនឹងស្ថានភាពទីផ្សារការងារ (ការផ្គត់ផ្គង់ និងតម្រូវការ) តម្រូវការជំនាញក្នុងការបំពេញការងារ...។

**សិស្ស៖** មានស្វ័យភាពក្នុងការសម្រេចចិត្តអំពីជម្រើសនៃការអប់រំបន្ត និងអាជីព។

**ការគាំទ្រពីក្រុមគ្រួសារ៖** ក្រុមគ្រួសាររបស់សិស្សផ្តល់ការគាំទ្រផ្លូវចិត្ត សម្ភារៈ ផ្អែកលើតម្រូវការជាក់ស្តែង ដើម្បីជួយសិស្សឱ្យសម្រេចគោលដៅជីវិត និងអាជីពរបស់ពួកគេ។

**ជំនាញ៖** សិស្សមានជំនាញក្នុងការសិក្សាសមស្រប ជំនាញទន់ ដើម្បីអភិវឌ្ឍការសិក្សា និងសមត្ថភាពខ្លួនឯងឱ្យកាន់តែប្រសើរ ដែលចាំបាច់សម្រាប់ទទួលបានការងារជោគជ័យ។

## ២.៥ ការញែកមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ចេញពី «ការប្រឹក្សាផ្លូវចិត្ត»

ជាការចាំបាច់ ដែលអ្នកអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ត្រូវសិក្សាស្វែងយល់ឱ្យបានច្បាស់អំពីភាពខុសគ្នានៃកម្មវិធីនេះ និងការផ្តល់ប្រឹក្សាផ្លូវចិត្ត។ មគ្គុទ្ទេសក៍អាជីព មានគោលបំណងជួយសិស្សឱ្យយល់អំពីចំណាប់អារម្មណ៍ និងបំណិនផ្ទាល់ខ្លួនរបស់ពួកគេ ខណៈការប្រឹក្សាផ្លូវចិត្តមាននិន្នាការផ្តោតលើសិស្សចំនួនតូចដែលមានបញ្ហាផ្ទាល់ខ្លួន និងបញ្ហាអាកប្បកិរិយាជាដើម។ នៅពេលចំណុចនេះក្លាយជាបញ្ហាដែលគេត្រូវផ្តោតការយកចិត្តទុកដាក់នោះ សិស្សភាគច្រើនអាចប្រឈមក្នុងការមិនទទួលបានផលប្រយោជន៍ពីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា។

## ២.៦ អត្ថប្រយោជន៍កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា

កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នឹងផ្តល់នូវអត្ថប្រយោជន៍ក្នុងការដោះស្រាយបញ្ហាកង្វះជំនាញ និងគម្លាតជំនាញ ក្នុងទីផ្សារការងារកម្ពុជានាពេលបច្ចុប្បន្ន និងអនាគត។ បន្ថែមលើនេះ កម្មវិធីនេះនឹងផ្តល់ផលជាវិជ្ជមានដល់ការរៀបចំគោលនយោបាយកម្រិតថ្នាក់ជាតិ និងភាគីពាក់ព័ន្ធដោយផ្ទាល់ដូចជា សិស្ស មាតាបិតាសិស្ស ឬអ្នកអាណាព្យាបាល អ្នកគ្រូលោកគ្រូ អ្នកគ្រូតាមមុខវិជ្ជា គណៈគ្រប់គ្រងនិងគ្រឹះស្ថានសិក្សា សហគ្រាសឯកជនក្នុងមូលដ្ឋានជាដើម។

### ២.៦.១ អត្ថប្រយោជន៍សម្រាប់សិស្ស

តាមរយៈកម្មវិធីនេះ សិស្សនឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- ចេះវាយតម្លៃសកម្មភាព និងលទ្ធផលសិក្សារបស់ខ្លួន
- ចេះពីរបៀបរៀន ស្គាល់ពីសមត្ថភាពវិញ្ញាណទាំង៥ និងចំណុចពិសេសនៃវិញ្ញាណរបស់ខ្លួន
- យល់ដឹងពីរបៀបអភិវឌ្ឍការរៀនសូត្ររបស់ខ្លួន និងស្គាល់ពីចំណុចខ្សោយក្នុងការរៀនសូត្ររបស់ខ្លួន ហើយចេះស្វែងរកជំនួយពាក់ព័ន្ធនឹងគ្រប់ស្ថានភាពបញ្ហាទាំងអស់

- មានឯករាជ្យភាព ចេះទទួលខុសត្រូវ ចេះរៀនជាក្រុម និងមានជំនាញអន្តរសកម្មភាព
- យល់ដឹងពីតួនាទីភារកិច្ចក្នុងនាមជាសិស្ស និងមានឥរិយាបថវិជ្ជមានក្នុងការសិក្សា
- យល់ដឹងឧបសគ្គផ្សេងៗក្នុងការសិក្សា និងវិធីសាស្ត្រក្នុងការពង្រឹងសមត្ថភាពចំណេះដឹង
- កាត់បន្ថយបញ្ហាអវត្តមានក្នុងការសិក្សាប្រចាំថ្ងៃ ទប់ស្កាត់អត្រាបោះបង់ការសិក្សា ជាពិសេសក្នុងដំណាក់កាលឆ្លងភូមិសិក្សា
- ទទួលបានការយកចិត្តទុកដាក់ជាពិសេសចំពោះសិស្សស្រី លើបញ្ហាយេនឌ័រ និងការសិក្សាការបម្រែបម្រួលវ័យ។ល។
- យល់ដឹងពីបុគ្គលិកលក្ខណៈ ចំណង់ចំណូលចិត្ត គុណតម្លៃផ្ទាល់ខ្លួន
- យល់ដឹងពីរបៀបស្វែងរកព័ត៌មាន ទិន្នន័យ មានបំណិនក្នុងការសម្រេចចិត្ត និងផ្តល់តម្លៃឱ្យខ្លួនឯង
- ទទួលបានការជួយជ្រោមជ្រែង និងណែនាំស្តីពីការតម្រង់ទិសវិជ្ជាជីវៈ ជម្រើសនៃការអប់រំបន្តជម្រើសអាជីព មុខរបរ នាថ្ងៃអនាគត
- មានមូលដ្ឋានក្នុងការរៀបចំផែនការសិក្សា និងមុខរបរ
- មានឱកាសក្នុងការអភិវឌ្ឍចំណេះដឹង សមត្ថភាពជំនាញ និងបុគ្គលិកលក្ខណៈ ក្នុងបរិយាកាសសង្គមចម្រុះជាតិសាសន៍ ដើម្បីក្លាយជាពលរដ្ឋពេញលេញ។

### ២.៦.២ អត្ថប្រយោជន៍សម្រាប់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស

មាតាបិតាសិស្ស ឬអ្នកអាណាព្យាបាលនឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- មានមូលដ្ឋានក្នុងការពិនិត្យតាមដានលើដំណើរការសិក្សារបស់កូនៗ
- បង្កើនទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងសាលារៀន និងមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស
- ផ្តល់ការគាំទ្រដល់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស ក្នុងការជំរុញលទ្ធផលការសិក្សាកូនៗ
- មានទំនុកចិត្ត និងមិនលំបាកក្នុងការណែនាំកូនៗឱ្យសិក្សារៀនសូត្រ។

### ២.៦.៣ អត្ថប្រយោជន៍សម្រាប់គ្រូមុខវិជ្ជា និងគ្រូបន្ទុកថ្នាក់

គ្រូមុខវិជ្ជា និងគ្រូបន្ទុកថ្នាក់នឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- សម្រាលបន្ទុកនៃការដោះស្រាយបញ្ហាប្រឈមរបស់សិស្ស
- លើកកម្ពស់វប្បធម៌ទំនាក់ទំនងនិងសហប្រតិបត្តិការរវាងសហការីក្នុងអង្គភាព
- ផ្តោតលើលទ្ធផលនៃការសិក្សារបស់សិស្ស ដើម្បីពង្រឹងប្រសិទ្ធភាព គុណភាពនៃការអប់រំ
- បង្កើនប្រសិទ្ធភាពក្នុងការបង្ហាត់បង្រៀនសិស្ស។

### ២.៦.៤ អត្ថប្រយោជន៍សម្រាប់គណៈគ្រប់គ្រង និងសាលារៀន

គណៈគ្រប់គ្រង និងសាលារៀន នឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- លទ្ធផលនៃការសិក្សាប្រចាំឆ្នាំរបស់សិស្ស កាន់តែល្អប្រសើរ
- កាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស ជាពិសេសក្នុងដំណាក់កាលឆ្លងភូមិសិក្សា

- ទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយពាក់ព័ន្ធស្ថានភាពសិស្ស ដែលប្រឈមនឹងការលំបាក
- រៀបចំផែនការកែលម្អសាលារៀនប្រចាំឆ្នាំចំគោលដៅល្អ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

### ២.៦.៥ អត្ថប្រយោជន៍សម្រាប់សហគ្រាសអាជីវកម្មក្នុងមូលដ្ឋាន

សហគ្រាសអាជីវកម្មក្នុងមូលដ្ឋាននឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- មានឱកាសបង្កើតកិច្ចសហការភាពជាដៃគូរវាងសាលារៀន និងក្រុមហ៊ុនសហគ្រាស
- មានឱកាសផ្សព្វផ្សាយពីសេវាកម្ម និងផលិតផលរបស់ខ្លួន
- មានឱកាសចូលរួមក្នុងដំណើរការអភិវឌ្ឍសាលារៀន និងការសិក្សារៀនសូត្ររបស់សិស្ស
- រួមចំណែកផ្តល់បទពិសោធដល់សិស្សឱ្យមានមូលដ្ឋានពង្រឹងសមត្ថភាពជំនាញ
- បង្កើតវេទិកាសន្ទនាបង្ហាញពីតម្រូវការជំនាញក្នុងការបំពេញការងារដល់សាលារៀន
- ទទួលបានកម្លាំងពលកម្មជំនាញសមស្របនឹងតម្រូវការ។

### ២.៦.៦ អត្ថប្រយោជន៍សម្រាប់ថ្នាក់ជាតិ

តាមរយៈកម្មវិធីនេះ នឹងចូលរួមចំណែកក្នុងការសម្រេចបាននូវគោលបំណងទាំង ៤ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានចែងក្នុងផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ និងផែនទីបង្ហាញផ្លូវស្តីពីអនុវិស័យអប់រំមធ្យមសិក្សាកម្ពុជា (CAMSEB) ឆ្នាំ២០៣០៖

- បណ្តុះមនសិការស្នេហាជាតិ ស្មារតីទទួលខុសត្រូវ ស្មោះត្រង់ និងមោទនភាពជាតិតាមរយៈការលើកកម្ពស់ការប្រកាន់នូវគំនិត គុណតម្លៃ បំណងប្រាថ្នារួមគ្នា ដើម្បីបង្កើតបាននូវសាមគ្គីភាពជាតិ និងអត្តសញ្ញាណជាតិ
- ផ្តល់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយដល់អ្នកសិក្សា ដើម្បីទទួលបានតុល្យភាពរវាងការអភិវឌ្ឍកាយសម្បទា បញ្ញា អារម្មណ៍ សោភណភាព និងស្មារតី
- ផលិតធនធានមនុស្សដែលមានចំណេះដឹង បំណិន និងសមត្ថភាព ដែលសមស្របតាមតម្រូវការទីផ្សារការងារ សម្រាប់សេដ្ឋកិច្ចពុទ្ធិប្រកបដោយពិពិធភាព ដែលអាចប្រកួតប្រណាំងនៅថ្នាក់តំបន់ និងសកលលោក
- រៀបចំអ្នកសិក្សាពេញមួយជីវិត សម្រាប់ការទំនាក់ទំនងសកល និងអន្តរបុគ្គលដែលអាចធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវនៅតាមថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលលោក ដើម្បីបង្កើតនូវពិភពលោកមួយឱ្យកាន់តែមានសុខសន្តិភាព និងប្រកបដោយចីរភាព
- បង្កើនការចូលរៀនរបស់សិស្ស និងគុណភាពនៃការអប់រំមធ្យមសិក្សាចំណេះទូទៅ រួមទាំងការអប់រំនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- លើកកម្ពស់ការផ្សារភ្ជាប់ទំនាក់ទំនងរវាងការអប់រំកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សា និងការចូលរួមពីតួអង្គពាក់ព័ន្ធ។

## ២.៧ សមាសភាពចូលរួម ដើម្បីភាពជោគជ័យនៃការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា

ដើម្បីឱ្យកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា អនុវត្តទៅបានប្រកបដោយភាពជោគជ័យ ចាំបាច់ត្រូវមានសមាសភាពចូលរួម និងគាំទ្រសំខាន់ៗដូចខាងក្រោម៖

- **កម្រិតថ្នាក់ជាតិ៖** ក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ) តាមរយៈ អន្តរាគមន៍កម្រិតគោលនយោបាយ ការរៀបចំផែនការសកម្មភាព និងយុទ្ធសាស្ត្រ ការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស... ដើម្បីធានាដល់ប្រសិទ្ធភាពនៃដំណើរការអនុវត្តកម្មវិធី
- **កម្រិតថ្នាក់ក្រោមជាតិ៖** មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈអន្តរាគមន៍ជាប្រព័ន្ធគាំទ្រផ្នែករដ្ឋបាល និងជំរុញឱ្យមានការចូលរួមគាំទ្រដល់ដំណើរការអនុវត្តកម្មវិធី ពីគ្រប់ភាគីពាក់ព័ន្ធនៅតាមមូលដ្ឋានរបស់ខ្លួន
- **កម្រិតសាលារៀន៖** គណៈគ្រប់គ្រងសាលារៀន បុគ្គលិកអប់រំទូទៅ និងគ្រូ ផ្តល់កិច្ចសហការគាំទ្រពេញលេញដល់ការអនុវត្តការងាររបស់គ្រូប្រឹក្សាតាមសាលារៀន
- **ស្ថាប័នដៃគូពាក់ព័ន្ធ៖** មជ្ឈមណ្ឌលការងារ គ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាល សមាគម/អង្គការសង្គមស៊ីវិល សហគ្រិនមូលដ្ឋាន និងក្រុមហ៊ុនសហគ្រាសពាក់ព័ន្ធទាំងអស់ ជាប្រភពធនធានដ៏សំខាន់ក្នុងការបង្កលទ្ធភាពដល់ការអនុវត្តកម្មវិធី មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។



## ៣. គោលការណ៍មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា

### ៣.១ គោលការណ៍មូលដ្ឋាន

ក្នុងការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា គ្រូប្រឹក្សាតាមសាលារៀន ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ជាមូលដ្ឋានមួយចំនួនដូចខាងក្រោម៖

- គ្រូប្រឹក្សាតាមសាលារៀន ត្រូវតែទទួលបានការបណ្តុះបណ្តាលផ្លូវការ ដើម្បីបំពេញការងាររបស់ខ្លួន
- គ្រូប្រឹក្សាតាមសាលារៀន ត្រូវប្រកាន់ខ្ជាប់តាមក្រមសីលធម៌វិជ្ជាជីវៈគ្រប់ពេលវេលា
- គ្រូប្រឹក្សាតាមសាលារៀន មិនមែនជាគ្រូប្រឹក្សាផ្នែកចិត្តសាស្ត្រឡើយ ហើយការងារជាអាទិភាពរបស់ខ្លួន គឺការផ្តល់សេវាមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាដល់សិស្ស និងភាគីពាក់ព័ន្ធ
- សេវាមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ត្រូវបានផ្តល់ជូនសិស្សទាំងអស់គ្នាដោយគ្មានការរើសអើង និងត្រូវធានានូវឱកាសក្នុងការប្រើប្រាស់សេវាដោយសមធម៌ ជាមួយនឹងការចៀសវាងឧបសគ្គផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ឬឧបសគ្គផ្សេងៗទៀត
- មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ត្រូវពិចារណាទៅលើលក្ខណៈពិសេសនៃអាយុ និងចំណង់ ចំណូលចិត្តរបស់សិស្ស
- គ្រូប្រឹក្សាតាមសាលារៀន ទទួលខុសត្រូវចំពោះការផ្តល់ជំនួយប្រកបដោយគុណភាពខ្ពស់ដល់សិស្ស រួមទាំងការអប់រំដែលទាក់ទងនឹងការស្គាល់ខ្លួនឯង និងចំណង់ចំណូលចិត្តផ្ទាល់ខ្លួន ព័ត៌មានវិជ្ជាជីវៈ និងសេវាប្រឹក្សាទល់មុខ
- សិស្សម្នាក់ៗត្រូវសម្រេចចិត្តដោយម្ចាស់ការទៅលើអនាគតផ្ទាល់ខ្លួន និងធ្វើស្វ័យសម្រេចចិត្តទាក់ទងនឹងការសិក្សា និងអាជីពមុខរបរ
- មគ្គុទ្ទេសក៍អាជីពនិងផ្តល់ប្រឹក្សា (ផ្តោតលើសេវាប្រឹក្សាទល់មុខជាពិសេស) គឺផ្អែកទៅលើសេចក្តីត្រូវការរបស់បុគ្គល និងតាមសំណើរបស់បុគ្គលដែលមានតម្រូវការ។

### ៣.២ ការបណ្តុះបណ្តាលគ្រូប្រឹក្សាតាមសាលារៀន

កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ត្រូវបានដាក់ឱ្យអនុវត្តតាមរយៈគ្រូប្រឹក្សាតាមសាលារៀន ដែលនឹងត្រូវជ្រើសរើសដោយប្រើយន្តការ ២ គឺ៖

- **ការបណ្តុះបណ្តាលបន្ត** ជាការជ្រើសរើសបេក្ខភាពចេញពីក្នុងចំណោមលោកគ្រូអ្នកគ្រូជាបុគ្គលិកអប់រំដែលមានក្របខណ្ឌស្រាប់ (លើកទឹកចិត្តដល់បុគ្គលិកអប់រំជាស្ត្រី) ដើម្បីផ្តល់ការបណ្តុះបណ្តាលលើផ្នែកបច្ចេកទេសប្រតិបត្តិការងារ ចំនួន ៦ ក្រេឌីត (ឬស្មើនឹង ១៣ ថ្ងៃ) ដោយមានរៀបចំវិញ្ញាបនបត្របញ្ជាក់ការសិក្សាជូន និងទទួលស្គាល់ជាគ្រូប្រឹក្សាតាមសាលារៀនដែលនឹងត្រូវបំពេញភារកិច្ចនៅអង្គភាពដើម។
- **ការបណ្តុះបណ្តាលថ្មី** ជាការជ្រើសរើសក្របខណ្ឌមុខងារថ្មីពីក្នុងចំណោមសិស្ស និស្សិត (លើកទឹកចិត្តដល់បេក្ខនារី) ដើម្បីផ្តល់ការបណ្តុះបណ្តាលក្នុងប្រព័ន្ធផ្អែកលើយន្តការនៃការបណ្តុះបណ្តាលគ្រូជាធរមាន នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋាន និងកម្រិតឧត្តម។

### ៣.២.១ ការបណ្តុះបណ្តាលបន្ត ( In-service Training )

ត្រូវបានជ្រើសរើសពីក្នុងចំណោមបុគ្គលិកអប់រំដែលមានក្របខណ្ឌស្រាប់ ដោយភ្ជាប់ជាមួយលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ជាបុគ្គលិកអប់រំកំពុងបម្រើការងារនៅក្នុងអង្គភាពគោលដៅដែលនឹងត្រូវអនុវត្តកម្មវិធី
- មានសញ្ញាបត្រមុខវិជ្ជាឯកទេសផ្នែកវិទ្យាសាស្ត្រសង្គមកាន់តែប្រសើរ
- មានបទពិសោធការងារក្នុងវិស័យអប់រំយ៉ាងតិច ២ ឆ្នាំ
- មានមនសិការវិជ្ជាជីវៈ និងក្រមសីលធម៌ល្អ អាចធ្វើការងារជាលក្ខណៈបុគ្គល និងក្រុម
- មានទេពកោសល្យក្នុងការសិក្សាស្រាវជ្រាវប្រធានបទពាក់ព័ន្ធ រៀបចំមេរៀន បណ្តុះបណ្តាល ដឹកនាំសិស្សធ្វើសកម្មភាព អប់រំតម្រង់ទិស ផ្តល់ការប្រឹក្សា លើកទឹកចិត្ត សម្របសម្រួល...
- មានឥរិយាបថវិជ្ជមានក្នុងការបំពេញការងារ
- ស្រឡាញ់ការសិក្សាស្រាវជ្រាវអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ
- យល់ដឹងពីនិន្នាការ និងព័ត៌មានទីផ្សារការងារក្នុងបរិបទកម្ពុជា និងតំបន់។

### ៣.២.២ ការបណ្តុះបណ្តាលដំបូង ( Pre-service Training )

ត្រូវបានជ្រើសរើសពីក្នុងចំណោមបេក្ខជន បេក្ខនារីទូទៅ ដើម្បីធ្វើការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយភ្ជាប់ជាមួយលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ជាសិស្ស និស្សិតដែលមិនទាន់មានក្របខណ្ឌជាមន្ត្រីរាជការសាធារណៈ ឬបុគ្គលិកអប់រំទូទៅ
- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម្រាប់ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- មានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើង (ឯកទេសខាងសង្គមសាស្ត្រ) សម្រាប់ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- មានមនសិការវិជ្ជាជីវៈ និងក្រមសីលធម៌ល្អ អាចធ្វើការងារជាលក្ខណៈបុគ្គល និងក្រុម
- មានទេពកោសល្យក្នុងការសិក្សាស្រាវជ្រាវប្រធានបទពាក់ព័ន្ធ រៀបចំមេរៀន បណ្តុះបណ្តាល ដឹកនាំសិស្សធ្វើសកម្មភាព អប់រំតម្រង់ទិស ផ្តល់ការប្រឹក្សា លើកទឹកចិត្ត សម្របសម្រួល...
- មានឥរិយាបថវិជ្ជមានក្នុងការបំពេញការងារ
- ស្រឡាញ់ការសិក្សាស្រាវជ្រាវអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ
- យល់ដឹងពីនិន្នាការ និងព័ត៌មានទីផ្សារការងារក្នុងបរិបទកម្ពុជា និងតំបន់។

## ៣.៣ តួនាទីភារកិច្ចគ្រូប្រឹក្សាតាមសាលារៀន

ដើម្បីឱ្យសម្រេចគោលដៅធំទាំង ៣ របស់កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដូចបានរៀបរាប់ខាងលើ គ្រូប្រឹក្សាតាមសាលារៀន ត្រូវអនុវត្តតួនាទីភារកិច្ចជាមូលដ្ឋានដូចខាងក្រោម៖

- ចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល និងវគ្គបំប៉នសមត្ថភាពផ្សេងៗ ដែលជាមូលដ្ឋានក្នុងការអភិវឌ្ឍជំនាញកាន់តែរឹងមាំ និងស៊ីជម្រៅ

- សិក្សាស្រាវជ្រាវព័ត៌មានថ្មីៗអំពីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា ព័ត៌មានទីផ្សារការងារ បំណិនសតវត្សរ៍ទី២១ ដើម្បីជាទុនក្នុងការអនុវត្តកម្មវិធីឱ្យកាន់តែមានប្រសិទ្ធភាព
- ត្រៀមលក្ខណៈសម្បត្តិក្នុងការផ្ដល់សេវាស្នូលទាំងបីរបស់គ្រូប្រឹក្សាតាមសាលារៀន (សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់ សេវាប្រឹក្សាទល់មុខ និងសេវាការងារបណ្ដាញ)
- ផ្ដល់ការសម្របសម្រួល និងគាំទ្រដល់ដំណើរការអភិវឌ្ឍរបស់សិស្សលើផ្នែកទាំងបីខាងលើ
- រួមចំណែកដោះស្រាយបញ្ហាប្រឈមរបស់សិស្ស និងសាលារៀន
- ណែនាំចង្អុលបង្ហាញផ្លូវដល់សិស្សពីប្រភពព័ត៌មានចាំបាច់នានាដែលពួកគេត្រូវការ
- ជួយត្រួសត្រាយផ្លូវ និងលើកទឹកចិត្តសិស្សក្នុងដំណាក់កាលឆ្លងភូមិសិក្សាពីបឋមសិក្សាថ្នាក់ទី៦ ឡើងមកថ្នាក់ទី៧ នៃមធ្យមសិក្សាបឋមភូមិ និងបន្តពីថ្នាក់ទី៩ ឡើងមកថ្នាក់ទី១០ នៃមធ្យមសិក្សាទុតិយភូមិ
- ជួយសិស្សក្នុងការរៀបចំផែនការសិក្សា និងមុខរបរ នាថ្ងៃអនាគតឱ្យបានសមស្របទៅនឹងចំណង់ចំណូលចិត្ត ឧបនិស្ស័យពីកំណើតរបស់គេ
- សហការជាមួយគ្រូបន្ទុកថ្នាក់ គ្រូតាមមុខវិជ្ជា បុគ្គលិកការិយាល័យ គណៈគ្រប់គ្រងសាលារៀន មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស អាជ្ញាធរ ឬភាគីពាក់ព័ន្ធនានា ដើម្បីរួមគ្នាពិនិត្យលទ្ធភាពដោះស្រាយបញ្ហាប្រឈមនានារបស់សិស្ស
- រៀបចំផែនការប្រតិបត្តិកម្មវិធីប្រចាំឆ្នាំ និងស្វ័យពិនិត្យវាយតម្លៃការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា
- សហការរៀបចំព្រឹត្តិការណ៍ផ្សេងៗរបស់គ្រឹះស្ថានសិក្សាដូចជា វេទិកាចែករំលែកបទពិសោធកម្មវិធីជំនួបមាតាបិតាសិស្ស ពិព័រណ៍ស្នាដៃសិស្ស ជំនួបអតីតសិស្សតាមជំនាន់...
- រៀបចំរបាយការណ៍ការងារ (តាមរបបកំណត់) ផ្ញើមកក្រសួងអប់រំ យុវជន និងកីឡា តាមឋានានុក្រមទទួលខុសត្រូវ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលគណៈគ្រប់គ្រងសាលារៀនបានប្រគល់ជូន។

បន្ថែមលើការទទួលខុសត្រូវជាមូលដ្ឋានខាងលើ គ្រូប្រឹក្សាតាមសាលារៀន ត្រូវអនុវត្តភារកិច្ចបច្ចេកទេសក្នុងការផ្ដល់សេវាស្នូលចំនួន ៣ គឺៈ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់ សេវាប្រឹក្សាទល់មុខ និងសេវាការងារបណ្ដាញ។

### ៣.៣.១ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់

ដើម្បីឱ្យសេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់មានដំណើរការល្អ គ្រូប្រឹក្សាតាមសាលារៀនត្រូវៈ

- សហការជាមួយគណៈគ្រប់គ្រងសាលារៀនរបស់ខ្លួន ដើម្បីស្នើសុំរៀបចំសេវាកាលវិភាគរៀន និងបង្រៀនប្រចាំសប្ដាហ៍ ផ្អែកលើខ្លឹមសារនៃសេចក្ដីណែនាំជាធរមាន
- អនុវត្តសេវាបង្រៀនមគ្គុទ្ទេសក៍ក្នុងថ្នាក់តាមការបែងចែករបស់គណៈគ្រប់គ្រងសាលារៀន
- អនុវត្តខ្លឹមសារសៀវភៅសិក្សាតាមកម្រិតថ្នាក់ ដែលក្រសួងអប់រំ យុវជន និងកីឡា បានអនុញ្ញាត ឱ្យប្រើប្រាស់ និងធ្វើបំណែងចែកកម្មវិធីសិក្សាតាមរូបភាពបត់បែន
- រៀបចំកិច្ចតែងការបង្រៀនមេរៀនមគ្គុទ្ទេសក៍ក្នុងថ្នាក់

- លើកសំណើសុំសម្ភារឧបទេសផ្សេងៗគាំទ្រដល់ការរៀន និងបង្រៀន ជូនគណៈគ្រប់គ្រងសាលារៀន ពិនិត្យលទ្ធភាពដោះស្រាយ
- ដឹកនាំសកម្មភាពរៀន និងបង្រៀន ដោយភាពបត់បែនទន់ភ្លន់ តាមស្ថានភាពជាក់ស្តែង។

### ៣.៣.២ សេវាប្រឹក្សាទល់មុខ

ដើម្បីឱ្យសេវាប្រឹក្សាទល់មុខមានដំណើរការល្អ គ្រូប្រឹក្សាតាមសាលារៀនត្រូវ៖

- ផ្តល់ការប្រឹក្សាទល់មុខដល់សិស្សជាលក្ខណៈបុគ្គលឯកជន ឬក្រុមតូច ដើម្បីជជែកពិភាក្សាស្វែងរកបញ្ហាប្រឈម និងលទ្ធភាពផ្សេងៗនៃដំណោះស្រាយ
- ប្រើប្រាស់តារាងពិន្ទុប្រចាំខែរបស់សិស្ស ដើម្បីពិនិត្យលទ្ធភាពក្នុងការណាត់សិស្សដែលមានបញ្ហារៀនយឺត មកជួបពិភាក្សាផ្តល់យោបល់ជំរុញលើកទឹកចិត្តសិស្ស
- លើកទឹកចិត្តសិស្សឱ្យសាកល្បងរិះរកដំណោះស្រាយលើបញ្ហាប្រឈមផ្ទាល់ខ្លួនរបស់គេ
- ប្រើប្រាស់ឧបករណ៍តេស្តដែលពាក់ព័ន្ធតាមស្ថានភាពជាក់ស្តែង ដើម្បីជាមូលដ្ឋានក្នុងការផ្តល់ប្រឹក្សាឱ្យកាន់តែមានប្រសិទ្ធភាព
- ផ្តោតការយកចិត្តទុកដាក់ខ្ពស់លើសិស្សស្រី
- ទុកដាក់កំណត់ហេតុពាក់ព័ន្ធការងារផ្តល់ប្រឹក្សាទល់មុខរបស់សិស្សម្នាក់ៗ។

### ៣.៣.៣ សេវាការងារបណ្តាញ

ដើម្បីឱ្យសេវាការងារបណ្តាញមានដំណើរការល្អ គ្រូប្រឹក្សាតាមសាលារៀនត្រូវ៖

- ធ្វើបញ្ជីរាយឈ្មោះបុគ្គល ឬស្ថាប័នគោលដៅបណ្តាញសំខាន់ៗដែលនឹងត្រូវធ្វើការជាមួយ
- សហការជាមួយគណៈគ្រប់គ្រងសាលា ឬដៃគូពាក់ព័ន្ធរួមមាន អាជ្ញាធរមានសមត្ថកិច្ច មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស ក្រុមហ៊ុនសហគ្រាស ឬអាជីវកម្មក្នុងមូលដ្ឋាន មជ្ឈមណ្ឌលការងារ គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដែលជាប្រភពបណ្តាញដ៏សំខាន់
- ធ្វើផែនការចុះជួបទំនាក់ទំនងបណ្តាញនីមួយៗ ដើម្បីបង្ហាញពីភាពចាំបាច់របស់សហគមន៍ក្នុងការលើកកម្ពស់គុណភាពសិក្សារបស់សិស្ស
- លើកសំណើសុំការឧបត្ថម្ភផ្សេងៗពីគណៈគ្រប់គ្រងសាលារៀន ដើម្បីសម្រួលដល់ការធ្វើដំណើរចុះជួបគោលដៅបណ្តាញ តាមរូបភាពបត់បែនទន់ភ្លន់
- ចូលរួមក្នុងព្រឹត្តិការណ៍សង្គមសំខាន់ៗ ដើម្បីកសាងបណ្តាញថ្មីឱ្យបានច្រើន។

## ៣.៤ តួនាទីភារកិច្ចគ្រូមុខវិជ្ជា និងគ្រូបន្ទុកថ្នាក់

ដើម្បីគាំទ្រឱ្យកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា អនុវត្តទៅដោយជោគជ័យ គ្រូបង្រៀនតាមមុខវិជ្ជាឯកទេស និងគ្រូបន្ទុកថ្នាក់ ត្រូវអនុវត្តតួនាទីភារកិច្ចក្នុងកម្រិតគាំទ្រដូចខាងក្រោម៖

- ជួយផ្សព្វផ្សាយអំពីកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដល់សិស្សតាមថ្នាក់រៀនដែលខ្លួនទទួលបន្ទុក និងបង្រៀន

- ផ្តល់កិច្ចសហការពេញលេញជាមួយគ្រូប្រឹក្សាតាមសាលារៀន ក្នុងការកំណត់មុខសញ្ញាសិស្ស ដែលត្រូវការជំនួយអន្តរាគមន៍ពីគ្រូប្រឹក្សាតាមសាលារៀន
- ពិភាក្សាពិនិត្យលទ្ធភាព និងរិះរកមធ្យោបាយផ្សេងៗ ដើម្បីរួមចំណែកដោះស្រាយបញ្ហារបស់សិស្ស ជាមួយគ្រូប្រឹក្សាតាមសាលារៀន។

## ៣.៥ តួនាទីភារកិច្ចគណៈគ្រប់គ្រងសាលារៀន

ដើម្បីគាំទ្រឱ្យកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា អនុវត្តទៅដោយជោគជ័យ គណៈគ្រប់គ្រងសាលារៀន ត្រូវអនុវត្តតួនាទីភារកិច្ចក្នុងកម្រិតគាំទ្រដូចខាងក្រោម៖

- ផ្សព្វផ្សាយដល់សិស្ស និងបុគ្គលិកអប់រំក្រោមឱវាទ ឱ្យយល់ជ្រួតជ្រាបពីសារៈសំខាន់នៃកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា និងជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់សេវានេះ
- បង្កលក្ខណៈងាយស្រួលដល់ការអនុវត្តកម្មវិធីនេះ និងសហការគាំទ្រ សម្របសម្រួល ដោះស្រាយបញ្ហាផ្សេងៗ ដើម្បីឱ្យការអនុវត្តកម្មវិធីមានដំណើរការរលូន
- រៀបចំផែនការកែលម្អសាលារៀន ផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយដាក់បញ្ចូលសកម្មភាពពាក់ព័ន្ធកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា
- ពិនិត្យលទ្ធភាពក្នុងការវិភាជន៍កញ្ចប់ថវិកាសាលារៀន ដើម្បីទ្រទ្រង់ដំណើរការអនុវត្តសកម្មភាពមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- ពិនិត្យលទ្ធភាពក្នុងការរៀបចំបន្ទប់ផ្តល់ប្រឹក្សា សម្រាប់គ្រូប្រឹក្សាតាមសាលារៀនអនុវត្តសកម្មភាពផ្តល់សេវាប្រឹក្សាទល់មុខ តាមស្ថានភាពជាក់ស្តែង
- រៀបចំសេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់ និងគ្រោងកញ្ចប់ថវិកាម៉ោងបន្ថែមគាំទ្រ ដោយភាពទន់ភ្លន់បត់បែន ក្នុងករណីចាំបាច់ដោយផ្អែកលើសេចក្តីណែនាំជាធរមាន
- កៀរគរប្រភពធនធាននានា ជួយដល់ដំណើរការអនុវត្តកម្មវិធីនេះ
- ណែនាំចង្អុលបង្ហាញគោលដៅបណ្តាញ ប្រភពធនធានគាំទ្រដល់គ្រូប្រឹក្សាតាមសាលារៀន
- ផ្សព្វផ្សាយ និងជ្រើសរើសបុគ្គលិកអប់រំដែលមានសក្តានុពល ឱ្យចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេស ជាគ្រូប្រឹក្សាតាមសាលារៀន តាមការរៀបចំរបស់នាយកដ្ឋានជំនាញ
- ជំរុញ និងលើកទឹកចិត្តគ្រូប្រឹក្សាតាមសាលារៀន អនុវត្តជាប្រចាំនូវសកម្មភាពមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា (សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់ ប្រឹក្សាទល់មុខ និងការងារបណ្តាញ)
- ផ្តល់ការគាំទ្រជាប្រចាំដល់ការអភិវឌ្ឍបណ្តាញ និងទំនាក់ទំនងរឹងមាំជាមួយក្រុមហ៊ុនសហគ្រាសអាជីវកម្មក្នុងមូលដ្ឋាន ឬភាគីពាក់ព័ន្ធផ្សេងៗទៀត
- ផ្តល់ការគាំទ្រ និងសហការសម្របសម្រួលជាមួយគ្រូប្រឹក្សាតាមសាលារៀន ក្នុងការរៀបចំព្រឹត្តិការណ៍ផ្សេងៗក្នុងគ្រឹះស្ថានសិក្សាដូចជា ជំនួបមាតាបិតាសិស្ស ពិព័រណ៍ស្នាដៃសិស្ស វេទិកាចែករំលែកបទពិសោធ ទស្សនកិច្ចសិក្សាទៅកាន់សហគ្រាសក្រុមហ៊ុនក្នុងមូលដ្ឋាន...។

## ៣.៦ តួនាទីភារកិច្ចគណៈកម្មការគ្រប់គ្រងសាលារៀន

ក្នុងដំណើរការជំរុញឱ្យការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នៅតាមសាលារៀនមធ្យមសិក្សាគោលដៅកាន់តែមានប្រសិទ្ធភាព គណៈកម្មការគ្រប់គ្រងសាលារៀនត្រូវ៖

- ជំរុញការអនុវត្ត និងការត្រួតពិនិត្យការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នៅតាមសាលារៀន ឱ្យមានប្រសិទ្ធភាពខ្ពស់
- ផ្សព្វផ្សាយអំពីសារៈសំខាន់នៃកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដល់សហគមន៍ អាជ្ញាធរមូលដ្ឋាន សំដៅជួយកៀរគរប្រភពធនធាន និងបង្កើតបណ្តាញការងារ ដល់គ្រូប្រឹក្សាតាមសាលារៀន
- លើកសំណើកញ្ចប់ថវិកា (មូលនិធិដំណើរការសាលារៀនសាធារណៈ) និងថវិកាបន្ថែមពីប្រភពផ្សេងៗ ទៀតតាមដែលអាចធ្វើទៅបាន គាំទ្រដល់ការអនុវត្តសកម្មភាពមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- សម្របសម្រួលការរៀបចំព្រឹត្តិការណ៍ផ្សេងៗដូចជា កម្មវិធីជួបជុំមាតាបិតាសិស្ស ពិព័រណ៍ សមិទ្ធផលស្នាដៃសិស្ស វេទិកាវាគ្មិនចែករំលែកបទពិសោធ។ល។
- សម្របសម្រួលបង្កើតទំនាក់ទំនងរវាងសាលារៀន សហគមន៍ និយោជិត-សហគ្រិនក្នុងមូលដ្ឋាន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត ចូលរួមចំណែកក្នុងការជំរុញឱ្យការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា មានដំណើរការទៅដោយរលូន។

## ៣.៧ តួនាទីភារកិច្ចអង្គភាពថ្នាក់ក្រោមជាតិ

ក្នុងដំណើរការជំរុញឱ្យការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នៅតាមសាលារៀនមធ្យមសិក្សាគោលដៅកាន់តែមានប្រសិទ្ធភាព មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវ៖

- ផ្តល់ការគាំទ្រផ្នែកស្មារតី បច្ចេកទេស និងធនធាន ដល់ការអនុវត្តកម្មវិធីនៅកម្រិតសាលារៀន
- កៀរគរប្រភពធនធាន ជំរុញ និងលើកទឹកចិត្តដល់សាលារៀនដែលអនុវត្តកម្មវិធីនេះតាមលទ្ធភាព និងរូបភាពផ្សេងៗ
- សម្របសម្រួលយន្តការពាក់ព័ន្ធផ្សេងៗ សំដៅឱ្យដំណើរការអនុវត្តកម្មវិធីអាចប្រព្រឹត្តទៅជាប្រក្រតីនៅកម្រិតសាលារៀន
- ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នៅតាមសាលាមធ្យមសិក្សាគោលដៅ។

## ៣.៨ តួនាទីភារកិច្ចអង្គភាពថ្នាក់ជាតិ (នាយកដ្ឋានជំនាញ)

ក្នុងដំណើរការជំរុញឱ្យការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នៅតាមសាលារៀនមធ្យមសិក្សាគោលដៅកាន់តែមានប្រសិទ្ធភាព នាយកដ្ឋានជំនាញត្រូវ៖

- កសាងគោលនយោបាយ ឯកសារគតិយុត្ត និងយន្តការគាំទ្រសមស្របតាមស្ថានភាពជាក់ស្តែង

- បណ្ដុះបណ្ដាល និងបំប៉នសមត្ថភាព គ្រូប្រឹក្សាតាមសាលារៀនទាំងអស់ និងផ្ដល់ជូនវិញ្ញាបនបត្រ បញ្ជាក់ការសិក្សាត្រឹមត្រូវ
- ផ្ដល់ជំនួយផ្នែកបច្ចេកទេស ដល់គ្រូប្រឹក្សាតាមសាលារៀន តាមរូបភាពផ្សេងៗ និងបង្កើតឱ្យមានសហគមន៍វិជ្ជាជីវៈគ្រូប្រឹក្សាតាមសាលារៀន
- ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា នៅតាមសាលាមធ្យមសិក្សាគោលដៅ។

# ៤. ឧបករណ៍ និងការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា

## ៤.១ ឧបករណ៍សម្រាប់សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់

### ៤.១.១ ឧបករណ៍សម្រាប់មធ្យមសិក្សាបឋមភូមិ

នៅកម្រិតមធ្យមសិក្សាបឋមភូមិ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តឱ្យប្រើប្រាស់ឯកសារ «**ការផ្ដល់ប្រឹក្សាអាជីព និងព័ត៌មានស្ដីពីការសិក្សាជំនាញ**» ដែលត្រូវបានចែកចេញជា ៤ ផ្នែកសំខាន់ៗ សម្រាប់ឱ្យគ្រូប្រឹក្សាតាមសាលារៀន ដកស្រង់មេរៀនយកទៅបង្រៀនសិស្សក្នុងថ្នាក់។ ឯកសារខាងលើ ត្រូវបានរៀបចំឡើងដោយផ្ដោតលើខ្លឹមសារមាតិកាសំខាន់ៗដូចខាងក្រោម៖

- ការសម្របសម្រួលនិងផ្ដល់ការគាំទ្រសិស្សក្នុងដំណាក់កាលឆ្លងភូមិសិក្សា និងពង្រឹងបំណិនសិក្សារៀនសូត្រនៅកម្រិតធ្យមសិក្សា
- ការជួយសិស្សក្នុងការបង្កើនពុទ្ធិចំណេះដឹងផ្ទាល់ខ្លួន និងវិធីក្នុងការគ្រប់គ្រងអារម្មណ៍ ការសម្របខ្លួនទៅនឹងបរិស្ថានថ្មីនៃការសិក្សា ការបង្កើតមិត្តភាពថ្មី ការសម្លឹងរកអ្នកដែលអាចផ្ដល់ការគាំទ្រដល់ដំណើរការសិក្សារបស់ពួកគេប្រចាំថ្ងៃ
- ការលើកទឹកចិត្តសិស្សឱ្យបង្កើតបំណងប្រាថ្នា ក្ដីស្រមៃនាថ្ងៃអនាគតពាក់ព័ន្ធនឹងជីវភាពរស់នៅ និងអាជីព ថាតើទិដ្ឋភាពអាជីពបែបណាដែលមានសារៈសំខាន់សម្រាប់ដំណើរជីវិតពួកគេ ហើយថាតើកត្តាអ្វីខ្លះដែលអាចជួយពួកគេឱ្យសម្រេចបាននូវអាជីពក្នុងក្ដីស្រមៃ និងកត្តាអ្វីដែលពួកត្រូវការដើម្បីសម្រេចគោលដៅជីវិត
- ការដឹកនាំសិស្សឱ្យយល់ដឹង សម្របខ្លួន លើកទឹកចិត្តផ្ទាល់ខ្លួន ក្នុងដំណើរការសិក្សាពេញមួយជីវិត
- ការលើកទឹកចិត្តក្នុងការស្វែងរកចំណុចខ្លាំង ចំណុចខ្សោយ បំណិនផ្ទាល់ខ្លួន បុគ្គលិកលក្ខណៈ និងវិធីសាស្ត្រក្នុងការអភិវឌ្ឍខ្លួន
- ការណែនាំសិស្សឱ្យសិក្សាស្វែងយល់ពីទិដ្ឋភាពផ្សេងៗដែលជះឥទ្ធិពលលើការសិក្សា ការរៀបចំផែនការសិក្សា និងមុខរបរ ស្វែងយល់ពីបុគ្គលិកលក្ខណៈ ចំណង់ចំណូលចិត្ត ជម្រើសមុខរបរ អាជីព និងព័ត៌មាននៃការអប់រំបណ្ដុះបណ្ដាល
- ការគាំទ្រសិស្សក្នុងការដោះស្រាយផ្ទាល់ខ្លួន ការប្រឈមនឹងបញ្ហាសម្ពាធផ្សេងៗ។

### ៤.១.២ ឧបករណ៍សម្រាប់មធ្យមសិក្សាទុតិយភូមិ

នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តឱ្យប្រើប្រាស់ឯកសារ **«មគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាណែនាំ សម្រាប់មធ្យមសិក្សាទុតិយភូមិ»** ដែលត្រូវបានចែកចេញជា ៤ ផ្នែកសំខាន់ៗ សម្រាប់ឱ្យគ្រូប្រឹក្សាតាមសាលារៀន ដកស្រង់មេរៀនយកទៅបង្រៀនសិស្សក្នុងថ្នាក់។ ឯកសារខាងលើ ត្រូវបានរៀបចំឡើងដោយផ្តោតលើខ្លឹមសារមាតិកាសំខាន់ៗដូចខាងក្រោម៖

- ការសម្របសម្រួល និងផ្តល់ការគាំទ្រសិស្សក្នុងដំណាក់កាលឆ្លងភូមិសិក្សា
- ការសិក្សាស្វែងយល់ពីវិធីសាស្ត្រផ្ទាល់ខ្លួនក្នុងការរៀនសូត្រ រួមបញ្ចូលទាំងការស្វែងរកព័ត៌មាន ដើម្បីគាំទ្រដល់ដំណើរការសិក្សាពេញមួយជីវិត
- ការធានាបានថាសិស្សនឹងមានទម្លាប់ក្នុងការផ្សារភ្ជាប់ចំណេះដឹង និងជំនាញសិក្សារបស់ខ្លួន ក្នុងដំណាក់កាលឆ្លងភូមិសិក្សាទៅឧត្តមសិក្សា ឬនៅក្នុងជីវភាពបំពេញការងារ ដើម្បីក្លាយខ្លួនជាពលរដ្ឋពេញលេញក្នុងសង្គម
- ការសិក្សាស្វែងយល់ពីចំណុចខ្លាំង ការរៀបចំផែនការអាជីព និងការដោះស្រាយបញ្ហា
- ការលើកកម្ពស់ការចូលរួមរបស់សិស្សក្នុងសកម្មភាពសង្គម គណនេយ្យភាព
- ការបន្សាំសិស្សអំពីប្រធានបទសំខាន់ៗនៃការអប់រំបន្តនាថ្ងៃអនាគត និងជីវិតបំពេញការងារ
- ការសិក្សាស្វែងយល់អំពីជំនាញក្នុងការស្វែងរកការងារ និងជំនាញបំពេញការងារ ព្រមទាំងគំនិត សហគ្រិនភាព។

## ៤.២ ការអនុវត្តកម្មវិធីសិក្សាសម្រាប់សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់

- **របាយម៉ោងបង្រៀនសម្រាប់កម្រិតថ្នាក់នីមួយៗ**
  - ១ម៉ោងសិក្សា/សប្តាហ៍
  - ៣៥សប្តាហ៍/ឆ្នាំសិក្សា
- **វិធីសាស្ត្របង្រៀន និងរៀន**
  - សិស្សមជ្ឈមណ្ឌល៖ សិស្សអនុវត្តកិច្ចផ្ទាល់ខ្លួន បំពេញការងារជាក្រុម ពិភាក្សាលើប្រធានបទ ស្រាវជ្រាវ ត្រិះរិះពិចារណា ដោះស្រាយបញ្ហា ឡើងធ្វើបទបង្ហាញ ល្បែងសិក្សា...។
- **សម្ភារឧបទេស**
  - សៀវភៅសិក្សាគោលតាមកម្រិតថ្នាក់
  - សៀវភៅកិច្ចតែងការបង្រៀន
  - សៀវភៅកំណត់ត្រារបស់គ្រូ
  - សន្លឹកកិច្ចការសិស្ស
  - ក្រដាសផ្ទាំង ខ្មៅដៃ ប៊ិក បន្ទាត់ គូលរ័ពណ៌ កន្ត្រៃ ការស្អិត ផ្ទាំងរូបភាពតំណាង...។

## ៥. ដំណើរការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា

### ៥.១ ការរៀបចំផែនការ និងថវិកាគាំទ្រ

**វត្ថុបំណង**

ជារៀងរាល់ឆ្នាំ សាលារៀនទាំងអស់តែងរៀបចំផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួន។ គណៈគ្រប់គ្រង និងគ្រូប្រឹក្សាតាមសាលារៀន ត្រូវធានាថាកញ្ចប់ថវិកាពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ត្រូវបានដាក់បញ្ចូលនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់សាលារៀន ដើម្បីអាចអនុវត្តកម្មវិធីការងារនេះ រួមទាំងការបង្កើតភាពជាដៃគូរវាងក្រុមហ៊ុនសហគ្រាស ឬអាជីវកម្មក្នុងមូលដ្ឋានជាមួយនឹងសាលារៀនមានដំណើរការទៅមុខដោយរលូន។

ក្នុងស្មារតីធានាប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធី គណៈគ្រប់គ្រងសាលារៀន ត្រូវដឹកនាំកិច្ចប្រជុំរៀបចំផែនការសកម្មភាពគាំទ្រមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដើម្បីរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ និងដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំសម្រាប់អង្គភាពរបស់ខ្លួនជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីពិនិត្យមើលធនធានចាំបាច់មួយចំនួនដូចជា ធនធានមនុស្ស ក្របខណ្ឌពេលវេលាដែលត្រូវអនុវត្តសកម្មភាព ធនធានសម្ភារៈដែលត្រូវការក្នុងពេលអនុវត្តសកម្មភាព និងធនធានថវិកាដែលសាលារៀនអាចចាត់ចែងបានតាមប្រភពថវិកាវិភាជន៍របស់រាជរដ្ឋាភិបាលប្រចាំឆ្នាំ ឬថវិកាគាំទ្ររបស់ដៃគូអភិវឌ្ឍ ទៅតាមដំណាក់កាលនីមួយៗ ថវិកាសប្បុរសជន សហគមន៍ ឬថវិកាដែលបានមកអំពីប្រភពផ្សេងទៀតរបស់សាលារៀន។

**គោលការណ៍ណែនាំ**

សាលារៀន ត្រូវប្រជុំដើម្បីរៀបចំផែនការកែលម្អសាលារៀន ផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំ ជាមួយអ្នកពាក់ព័ន្ធដូចជា គណៈកម្មការគ្រប់គ្រងសាលារៀន គ្រូបង្រៀន គ្រូប្រឹក្សាតាមសាលារៀន ក្រុមប្រឹក្សាកុមារ និងយុវជន ដោយបញ្ចូលនូវផែនការសកម្មភាពកមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា សម្រាប់គ្រឹះស្ថានមធ្យមសិក្សា។ បន្ទាប់ពីបានសេចក្តីព្រាងផែនការទាំងនោះហើយ គណៈគ្រប់គ្រងសាលារៀន ត្រូវប្រជុំផ្សព្វផ្សាយផែនការនោះបុគ្គលិកអប់រំទូទៅ មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស អាជ្ញាធរមូលដ្ឋាន តំណាងសហគ្រាស ឬផ្នែកឯកជន ដើម្បីចូលរួមផ្តល់មតិយោបល់កែលម្អ។

ដើម្បីធានានូវការអនុវត្តផែនការទាំងអស់ខាងលើបានល្អ គណៈគ្រប់គ្រងសាលារៀនត្រូវរៀបចំការប្រជុំប្រចាំត្រីមាស ដោយមានការចូលរួមពីគណៈនាយក គ្រូប្រឹក្សាតាមសាលារៀន លោកគ្រូ អ្នកគ្រូបន្ទុកថ្នាក់គ្រប់កម្រិត គណៈកម្មការគ្រប់គ្រងសាលារៀន តំណាងមាតាបិតាសិស្ស និងតំណាងសហគ្រាស ឬផ្នែកឯកជន ដើម្បីពិនិត្យមើលវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាព បញ្ហាប្រឈម ដំណោះស្រាយនានា ក្នុងន័យកែលម្អការរៀបចំសកម្មភាពនៅឆ្នាំក្រោយៗទៀតឱ្យល្អប្រសើរ កាន់តែមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ និងធានាបាននូវការគិតគូរខ្ពស់អំពីការចូលរួមរបស់ស្ត្រីក្នុងដំណើរការអភិវឌ្ឍសាលារៀន។ *(ឧបសម្ព័ន្ធ១-២)*

## ៥.២ ការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា

### ៥.២.១ ការតម្រង់ទិសមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ក្នុងកម្មវិធីបើកបវេសនកាល

- **វត្ថុបំណង៖** បង្កឱកាសឱ្យសាលារៀនបានចែករំលែកព័ត៌មានអប់រំ និងតម្រូវការនានារបស់សាលារៀនដល់សហគមន៍ ដើម្បីទទួលបានការគាំទ្រ និងកិច្ចសហការល្អ។

- **គោលការណ៍ណែនាំ**

នៅដើមឆ្នាំសិក្សា សាលារៀននីមួយៗតែងបើកវេទិកាជួបជុំរយៈពេលកន្លះថ្ងៃជាមួយអ្នកពាក់ព័ន្ធដូចជាថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ឬបុគ្គលិកអប់រំថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាជ្ញាធរដែនដីសហគមន៍ មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស តំណាងវិស័យឯកជន អ្នកគ្រូលោកគ្រូ សិស្សានុសិស្ស និងដៃគូអភិវឌ្ឍ ដើម្បីរំឭកនិងផ្សព្វផ្សាយដល់អ្នកចូលរួមអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាលលើវិស័យអប់រំ ចក្ខុវិស័យ ទិសដៅ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ការចូលរួមរបស់វិស័យឯកជន និងសហគមន៍ក្នុងកិច្ចដំណើរការសាលារៀន និងការចែករំលែកព័ត៌មាននានាក្នុងឆ្នាំសិក្សាថ្មីដែលនឹងចូលមកដល់។ កម្មវិធីប្រចាំឆ្នាំនេះ គឺជាពេលវេលាដ៏ល្អសម្រាប់ផ្តល់ការតម្រង់ទិសអំពីកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា ដើម្បីឱ្យអ្នកចូលរួមជ្រួតជ្រាបអំពីបេសកកម្ម និងសារៈសំខាន់របស់កម្មវិធីនេះ។ ដើម្បីឱ្យមានសមភាពយេនឌ័រ គណៈគ្រប់គ្រងសាលារៀន គួររៀបចំលិខិតអញ្ជើញអ្នកចូលរួមដោយរំលេចឱ្យឃើញពីវត្តមានដ៏សំខាន់របស់ស្ត្រីក្នុងកម្មវិធីបើកបវេសនកាលនេះ។

គ្រូប្រឹក្សាតាមសាលារៀន ដើរតួជាវាគ្មិនក្នុងការណែនាំអំពីសញ្ញាណនៃការសិក្សា និងសារៈសំខាន់នៃសេវាមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដល់អង្គវេទិការួម។ បន្ថែមលើនេះ គ្រូប្រឹក្សាតាមសាលារៀន ក៏នឹងត្រូវដើរតួនាទីជាអ្នកសម្របសម្រួលកិច្ចពិភាក្សាក្រុមរវាងអ្នកចូលរួមកម្មវិធីទាំងអស់ ដែលនឹងត្រូវបែងចែកជាក្រុមពិភាក្សាតូចៗចំនួន ៤-៦ ក្រុម ដោយផ្តោតសំខាន់លើប្រធានបទផ្សេងៗពាក់ព័ន្ធនឹងការអប់រំ បញ្ហាសមភាពយេនឌ័រនិងការទទួលបានសេវាអប់រំរបស់សិស្សស្រី ឬលទ្ធភាពនៃការចូលរួមចំណែកពង្រឹងគុណភាពរៀន និងបង្រៀនរបស់សាលារៀនជាដើម។

### ៥.២.២ ការតម្រង់ទិសសិស្សក្នុងដំណាក់កាលឆ្លងភូមិសិក្សា

- **វត្ថុបំណង៖** តម្រង់ទិសសិស្សថ្មីដែលទើបឆ្លងភូមិសិក្សា (ថ្នាក់ទី៧ និងថ្នាក់ទី១០) ឱ្យយល់ដឹងអំពីមជ្ឈដ្ឋានសិក្សា និងបរិយាកាសនៃការសិក្សាថ្មី ដែលពួកគេនឹងត្រូវឆ្លងកាត់ក្នុងជីវិតសិក្សាកម្រិតមធ្យមសិក្សា។

- **គោលការណ៍ណែនាំ**

សិស្សថ្នាក់ទី៧ថ្មី និងថ្នាក់ទី១០ថ្មី គឺជាក្រុមសិស្សដែលទើបឆ្លងផុតពីបឋមសិស្សា និងមធ្យមសិក្សាបឋមភូមិ។ ពួកគេ គឺជាគោលដៅសំខាន់ដំបូងគេ ដែលគ្រូប្រឹក្សាតាមសាលារៀនត្រូវយកចិត្តទុកដាក់ ពីព្រោះពួកគេត្រូវប្រឈមនឹងមជ្ឈដ្ឋានសិក្សាថ្មី ទាំងចម្ងាយផ្លូវ បន្ទប់សិក្សា មុខវិជ្ជាសិក្សា សម្ភារៈសិក្សា គ្រូបង្រៀន និងមិត្តភក្តិថ្មីជាដើម។ ពួកគេត្រូវការការតម្រង់ទិសជាពិសេស ដើម្បីអាចឱ្យពួកគេសម្របខ្លួននឹងមជ្ឈដ្ឋានថ្មីនេះបាន ប្រកបដោយភាពកក់ក្តៅ និងភាពជឿជាក់។ ការណ៍នេះ គ្រូប្រឹក្សាតាមសាលារៀន គឺជាអ្នកសម្រប

សម្រួលដ៏មានសក្តានុពល ក្នុងការត្រួសត្រាយចែករំលែកព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងដំណើរការសិក្សាក្នុងភូមិសិក្សាថ្មីនេះ។

ដើម្បីជាផ្នែកមួយនៃការសម្រាលសម្ពាធផ្លូវអារម្មណ៍របស់សិស្សថ្មី នៅថ្ងៃបន្ទាប់ពីការបើកបវេសនកាលដំបូង គ្រូប្រឹក្សាតាមសាលារៀន ត្រូវសហការជាមួយគណៈគ្រប់គ្រងសាលារៀន ក្នុងការបង្កើតជាវេទិកាជួបជុំតម្រង់ទិសសិស្សដាច់ដោយឡែកពីគ្នាសម្រាប់សិស្សថ្នាក់ទី៧ (អាចរៀបចំនៅពេលព្រឹក) និងសិស្សថ្នាក់ទី១០ (អាចរៀបចំនៅពេលរសៀល)។ ប្រធានបទសំខាន់ៗនៃការជួបជុំនេះ គួរតែត្រូវបានលើកអំពីបរិកាសនៃការសិក្សា របៀបរៀនឱ្យទទួលបានជោគជ័យ សេវាមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា និងប្រធានបទចាំបាច់ដទៃទៀតតាមស្ថានភាពជាក់ស្តែងនៃសាលារៀននីមួយៗ។

ក្នុងដំណាក់កាលនេះ ជាការចាំបាច់គ្រូប្រឹក្សាតាមសាលារៀនត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់លើសិស្ស ស្រី។ ជាទូទៅសិស្សស្រី ខុសពីសិស្សប្រុស លើបញ្ហាប្រឈមនានាដូចជា សំណួរ ការពិចារណាដំណើរចម្រើនលូតលាស់នៃវ័យ និងរនាំងសង្គម ដែលបញ្ហាទាំងនេះអាចជាចំណែកមួយនៃការបោះបង់ការសិក្សា ប្រសិនជាពួកគេខ្វះការយកចិត្តទុកដាក់។ ដូច្នេះ គ្រូប្រឹក្សាតាមសាលារៀន ត្រូវដោះស្រាយបញ្ហានេះឱ្យបាន សមស្រប។ គ្រូប្រឹក្សាតាមសាលារៀន មិនត្រូវឆ្លើយតបទៅនឹងបញ្ហាទាំងនេះដោយសម្អាងទៅលើតែបញ្ហា ប្រពៃណីមួយមុខប៉ុណ្ណោះទេ តែត្រូវឈរលើគោលការណ៍សមភាពយេនឌ័រ និងការយល់ដឹងជាទូទៅអំពី ស្ថានភាពចិត្តសាស្ត្ររបស់យុវវ័យដំណាក់កាលនេះ។

### ៥.២.៣ ការតម្រង់ទិសសិស្សមធ្យមសិក្សាទុតិយភូមិ

- **វត្ថុបំណង៖** តម្រង់ទិសសិស្ស ក្នុងការជ្រើសរើសប្រភេទថ្នាក់រៀនតាមបណ្តុំមុខវិជ្ជា និងត្រៀមខ្លួនជ្រើសរើសជំនាញសិក្សានៅកម្រិតឧត្តមសិក្សា និងការដាក់ស្នើអាហារូបករណ៍ផ្សេងៗ។
- **គោលការណ៍ណែនាំ**

ជាទូទៅ នៅចុងត្រីមាសទី២នៃឆ្នាំសិក្សានីមួយៗ សិស្សថ្នាក់ទី១០ ទាំងអស់ នឹងត្រូវពិចារណាសម្រេចចិត្តជ្រើសរើសប្រភេទថ្នាក់រៀនតាមបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រសង្គម នៅថ្នាក់ទី១១ នៃឆ្នាំសិក្សាថ្មី។ ជាមួយគ្នានេះ ចំពោះសិស្សថ្នាក់ទី១២វិញ ពួកគេក៏ត្រូវត្រៀមខ្លួនបំពេញសំណុំឯកសារស្នើសុំអាហារូបករណ៍ក្រសួងអប់រំ យុវជន និងកីឡា ដោយត្រូវជ្រើសរើសមុខជំនាញសិក្សាឧត្តមសិក្សាជាមុនផងដែរ នៅអំឡុងដើមត្រីមាសទី២ នៃឆ្នាំសិក្សា។ ដំណាក់កាលនេះ ជាពេលវេលាដ៏សំខាន់របស់សិស្សម្នាក់ៗ ក្នុងការកំណត់ពីជម្រើសនៃការអប់រំបន្តរបស់ខ្លួន ឬថាជាពេលវេលានៃការត្រៀមខ្លួនចាប់យកជំនាញច្បាស់លាស់សម្រាប់គោលដៅអាជីពនាពេលអនាគត។

គ្រូប្រឹក្សាតាមសាលារៀន ត្រូវសហការជាមួយគណៈគ្រប់គ្រងសាលារៀន ដើម្បីពិនិត្យលទ្ធភាពដាក់ចេញនូវក្របខណ្ឌកម្មវិធីការងារជាក់ស្តែងដាច់ដោយឡែកគ្នា ក្នុងការរៀបចំវេទិកាអប់រំតម្រង់ទិសសិស្សឱ្យយល់ជ្រួតជ្រាប អំពីរបៀបនៃការជ្រើសរើសថ្នាក់រៀនតាមបណ្តុំមុខវិជ្ជា សម្រាប់សិស្សថ្នាក់ទី១០ ដោយប្រើប្រាស់ឯកសារណែនាំស្តីពី «**ការជ្រើសរើសប្រភេទថ្នាក់វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម ឬជំនាញបច្ចេកទេសវិជ្ជាជីវៈ**» ដែលក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំឡើង។ វេទិកាតម្រង់ទិសមួយទៀត ត្រូវរៀបចំឡើងសម្រាប់ក្រុមសិស្សថ្នាក់ទី១២ ដើម្បីណែនាំអំពីរបៀបនៃការបំពេញទម្រង់ស្នើសុំអាហារូបករណ៍ និងមូលដ្ឋាន

ក្នុងការជ្រើសរើសមុខជំនាញសិក្សាដោយ ផ្អែកលើសមត្ថភាពបុគ្គលិកលក្ខណៈ និងទេពកោសល្យផ្ទាល់ខ្លួនរបស់សិស្សម្នាក់ៗ។ ក្នុងកម្មវិធីនេះ គ្រូប្រឹក្សាតាមសាលារៀនគួរប្រើ**តេស្ត RAISEC ឬកម្មវិធីត្រីវិស័យ** ដើម្បីជាជំនួយស្មារតីដល់សិស្សគ្រប់រូប ក្នុងការធ្វើស្វ័យសម្រេចចិត្តបានត្រឹមត្រូវ និងជាពិសេសត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការជំរុញលើកទឹកចិត្តសិស្សស្រី ឱ្យពួកគេមានទំនុកចិត្តកាន់តែខ្លាំងក្នុងការទទួលបានឱកាសបន្តការសិក្សាទៅខាងមុខទៀត ព្រមទាំងមានលទ្ធភាពដណ្តើមយកភាពជោគជ័យក្នុងអាជីពការងារដូចបុរសដែរ។

## ៥.២.៤ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ

- ***វត្ថុបំណង៖*** ផ្តល់ពុទ្ធិដល់សិស្សពាក់ព័ន្ធវិធីសាស្ត្រក្នុងការអភិវឌ្ឍខ្លួន របៀបរៀន ទិដ្ឋភាពផ្សេងៗដែលជះឥទ្ធិពលលើការសិក្សា ការរៀបចំផែនការសិក្សា និងមុខរបរ ស្វែងយល់ពីបុគ្គលិកលក្ខណៈ ចំណង់ចំណូលចិត្ត ជម្រើសមុខរបរ អាជីព និងព័ត៌មាននៃការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ។

- ***គោលការណ៍ណែនាំ***

គ្រូប្រឹក្សាតាមសាលារៀន ត្រូវស្នើសុំកិច្ចសហការពីគណៈគ្រប់គ្រងសាលារៀន ដើម្បីដាក់បញ្ចូលសេវាម៉ោងមគ្គុទ្ទេសក៍ក្នុងថ្នាក់ទៅក្នុងសេវារៀន និងបង្រៀនប្រចាំសប្តាហ៍តាមកម្រិតថ្នាក់នីមួយៗ ដោយត្រូវអនុលោមតាមសេចក្តីណែនាំលេខ ៤០ អយក.សណន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការរៀបចំសេវាប្រឹក្សាអាជីពនៅតាមគ្រឹះស្ថានមធ្យមសិក្សា និងប្រើប្រាស់ឯកសារ «**ការផ្តល់ប្រឹក្សាអាជីព និងព័ត៌មានស្តីពីការសិក្សាជំនាញ**» របស់ក្រសួងអប់រំ យុវជន និងកីឡា ជាឯកសារគោលក្នុងការបង្រៀន។ ដើម្បីឱ្យសម្រេចវត្ថុបំណង និងទិសដៅមេរៀននីមួយៗតាមកម្រិតថ្នាក់ គ្រូប្រឹក្សាតាមសាលារៀន ត្រូវធ្វើបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ កិច្ចតែងការបង្រៀនឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំជាធរមាន និងត្រៀមរៀបចំសម្ភារៈចាំបាច់សម្រាប់ការរៀន និងបង្រៀន តាមតម្រូវការជាក់ស្តែងរបស់មេរៀននីមួយៗ។ ក្នុងការអនុវត្តសកម្មភាពបង្រៀន និងរៀនដូចជា ល្បែងសិក្សា ការងារក្រុម ការងារជាគូ... គ្រូប្រឹក្សាតាមសាលារៀន គួរផ្តល់អាទិភាព និងយកចិត្តទុកដាក់ក្នុងការពង្រឹងការចូលរួមរបស់សិស្សស្រីឱ្យបានផុលផុស។ *(ឧបសម្ព័ន្ធ៣)*

## ៥.២.៥ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ

- ***វត្ថុបំណង៖*** ផ្តល់ពុទ្ធិដល់សិស្សពាក់ព័ន្ធវិធីសាស្ត្រក្នុងការអភិវឌ្ឍខ្លួន ការដោះស្រាយបញ្ហា ជំនាញទន់ជំនាញបំពេញការងារ ការត្រៀមខ្លួនទៅកាន់ជម្រើសនៃការអប់រំបន្ត និងជម្រើសអាជីព និងសហគ្រិនភាព។

- ***គោលការណ៍ណែនាំ***

គ្រូប្រឹក្សាតាមសាលារៀន ត្រូវស្នើសុំកិច្ចសហការពីគណៈគ្រប់គ្រងសាលារៀន ដើម្បីដាក់បញ្ចូល សេវាម៉ោងមគ្គុទ្ទេសក៍ក្នុងថ្នាក់ទៅក្នុងសេវារៀន និងបង្រៀនប្រចាំសប្តាហ៍តាមកម្រិតថ្នាក់នីមួយៗ ដោយត្រូវអនុលោមតាមសេចក្តីណែនាំលេខ ៤០ អយក.សណន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការរៀបចំសេវាប្រឹក្សាអាជីពនៅតាមគ្រឹះស្ថានមធ្យមសិក្សា និងប្រើប្រាស់ឯកសារ «**សៀវភៅណែនាំស្តីពីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា សម្រាប់មធ្យមសិក្សាទុតិយភូមិ**» របស់ក្រសួងអប់រំ យុវជន និងកីឡា ជាឯកសារគោលក្នុងការបង្រៀន។ ដើម្បីឱ្យសម្រេចវត្ថុបំណង និងទិសដៅមេរៀននីមួយៗតាមកម្រិតថ្នាក់ គ្រូប្រឹក្សាតាមសាលារៀន ត្រូវធ្វើបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ កិច្ចតែងការបង្រៀនឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំជា

ធរមាន និងត្រៀមរៀបចំសម្ភារៈចាំបាច់សម្រាប់ការរៀន និងបង្រៀន តាមស្ថានភាពនៃតម្រូវការជាក់ស្តែងរបស់មេរៀននីមួយៗ។ ក្នុងការអនុវត្តសកម្មភាព បង្រៀន និងរៀនដូចជា ល្បែងសិក្សា ការងារក្រុម ការងារជាគូ... គ្រូប្រឹក្សាតាមសាលារៀន គួរផ្តល់អាទិភាព និងយកចិត្តទុកដាក់ក្នុងការពង្រឹងការចូលរួមរបស់សិស្សស្រីឱ្យបានផុលផុស។*(ឧបសម្ព័ន្ធ៣)*

### ៥.២.៦ សេវាផ្តល់ប្រឹក្សាទល់មុខ

- **វត្ថុបំណង៖** ផ្តល់ការគាំទ្រផ្នែកស្មារតីដល់សិស្សតាមរយៈការរៀបចំកិច្ចសន្ទនាទល់មុខក្នុងលក្ខណៈជាការតម្រង់ទិស ឬស្វែងរកលទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រឈមផ្សេងៗពាក់ព័ន្ធការសិក្សារបស់សិស្ស។
- **គោលការណ៍ណែនាំ**

សិស្សកម្រិតមធ្យមសិក្សា ចាប់ពីថ្នាក់ទី៧ ដល់ទី១២ ត្រូវទទួលបានការគាំទ្រលើវិធីសាស្ត្រដោះស្រាយបញ្ហា ដើម្បីជួយសម្រាលក្តីកង្វល់ ឧបសគ្គចំពោះការសិក្សារៀនសូត្រ ឬបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេ។ ការគាំទ្រលើដំណើរការសិក្សារបស់សិស្ស នឹងជួយបង្កើនប្រសិទ្ធភាពរៀន និងលទ្ធផលសិក្សាប្រកបដោយភាពវិជ្ជមាន។ គ្រូប្រឹក្សាតាមសាលារៀន ត្រូវផ្តល់កិច្ចអន្តរាគមន៍លើបញ្ហាប្រឈមមួយចំនួនរបស់សិស្សដូចជាការមករៀនយឺត ការរៀនយឺត ការស្វែងរកអាជីពក្នុងក្តីសុបិន ការរៀបចំផែនការសិក្សាដែលគាំទ្រដល់ជម្រើសអាជីពនាពេលអនាគត វិបត្តិគ្រួសារ អំពើហិង្សា បញ្ហាសុខភាពជាដើម។ គ្រូប្រឹក្សាតាមសាលារៀនត្រូវផ្សព្វផ្សាយដល់សិស្សអំពីការផ្តល់សេវាប្រឹក្សាទល់មុខ និងលើកទឹកចិត្តសិស្សឱ្យមកជួបប្រឹក្សាទល់មុខជាមួយខ្លួន ដោយបញ្ជាក់សិស្សអំពីការរក្សាការសម្ងាត់សម្រាប់សិស្សដែលមកទទួលសេវា។ មួយវិញទៀត ការកំណត់មុខសញ្ញាសិស្ស ដែលត្រូវការកិច្ចអន្តរាគមន៍ពីគ្រូ ត្រូវការកិច្ចសហការគ្នាដោយផ្ទាល់រវាងគ្រូប្រឹក្សាតាមសាលារៀន គ្រូបន្ទុកថ្នាក់គ្រប់កម្រិត គ្រូមុខវិជ្ជា សិស្ស និងគណៈគ្រប់គ្រងសាលារៀន។ ក្នុងករណីគ្រូប្រឹក្សាតាមសាលារៀន ត្រូវការប្រមូលព័ត៌មានសិស្សពីសហគមន៍ សាលារៀនគួររៀបចំការឧបត្ថម្ភខ្លះលើសោហ៊ុយចំណាយក្នុងការធ្វើដំណើរតាមលទ្ធភាពជាក់ស្តែង ក្នុងចំនួនកំណត់មួយ។

គ្រូប្រឹក្សាតាមសាលារៀន ត្រូវប្រមូលព័ត៌មានទូទៅ ឬស្ថិតិសិស្ស ពីគ្រូបន្ទុកថ្នាក់ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីចងក្រងជាឯកសារព័ត៌មានទាក់ទងនឹងអតិថិជនគោលដៅ ដែលជាក្រុមសិស្សងាយរងគ្រោះទាំងនោះ។ គ្រូត្រូវចាត់ប្រភេទក្រុមសិស្សដូចជា ក្រុមសិស្សមករៀនយឺត ក្រុមសិស្សអវត្តមានច្រើន ក្រុមសិស្សរៀនយឺត ក្រុមសិស្សរៀនពូកែ ដើម្បីងាយស្រួលរៀបចំផែនការប្រឹក្សាទល់មុខជាក្រុម។ ការផ្តល់ប្រឹក្សាទល់មុខ អាចនឹងត្រូវរៀបចំជាលក្ខណៈបុគ្គល ឬក្រុមតូចៗដែលកំណត់អតិថិជនត្រឹមតែ០៤នាក់យ៉ាងច្រើន។ ករណីសិស្សដែលប្រឈមនឹងបញ្ហាវិបត្តិគ្រួសារ កត្តាជីវភាពគ្រួសារ និងបញ្ហាសុខភាពផ្ទាល់ខ្លួន ត្រូវទទួលការផ្តល់ប្រឹក្សាទល់មុខម្នាក់ទល់ម្នាក់ (គ្រូប្រឹក្សាតាមសាលារៀន និងសិស្ស) ពីព្រោះសិស្សត្រូវការទំនុកចិត្ត និងភាពសម្ងាត់។ សិស្សស្រី ក៏ជាក្រុមគោលដៅសំខាន់ដែលគ្រូប្រឹក្សាតាមសាលារៀន ត្រូវផ្តល់ការគាំទ្រជាពិសេសជាងសិស្សប្រុស ដ្បិតសិស្សស្រីអាចមានបញ្ហាប្រឈមច្រើនជាងសិស្សប្រុសទាំងលើទិដ្ឋភាពនៃការធ្វើដំណើរ ដំណើរការរៀនសូត្រ ការលូតលាស់របស់វ័យ ទំនាក់ទំនងសង្គម និងស្ថានភាពគ្រួសារជាដើម។ រយៈពេលនៃការផ្តល់ប្រឹក្សាទល់មុខក្នុងសិស្សម្នាក់ ឬមួយក្រុម គួររៀបចំមិនឱ្យលើសពី ៣០នាទី ឬអាចយូរជាងនេះក្នុងករណីចាំបាច់ ឬករណីដែលត្រូវការប្រើប្រាស់ឧបករណ៍តេស្តពាក់ព័ន្ធ។

ដើម្បីគាំទ្រការរៀបចំដំណើរការប្រឹក្សាទល់មុខស្របតាមលក្ខណៈបច្ចេកទេស គណៈគ្រប់គ្រងសាលារៀន ត្រូវផ្ដួចផ្ដើមរៀបចំបន្ទប់ប្រឹក្សាយោបល់ដាច់ដោយឡែក និងឆ្ងាយពីទីចាត់ការ ដោយយោងស្មារតីនៃសេចក្ដីណែនាំលេខ៤០អយក.សណន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧។ *(ឧបសម្ព័ន្ធ៤-៥)*

## ៥.២.៧ ការប្រើប្រាស់កម្មវិធីត្រីវិស័យ

**វត្ថុបំណង៖** ផ្ដល់ឱ្យសិស្សចាប់ពីថ្នាក់ទី៩ ដល់ថ្នាក់ទី១២ នូវការស្វែងយល់អំពីបុគ្គលិកលក្ខណៈ សមត្ថភាព ទេពកោសល្យរបស់ខ្លួន ព័ត៌មានអំពីប្រភេទមុខរបរ គ្រឹះស្ថានសិក្សា ព័ត៌មានទីផ្សារការងារ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្តជ្រើសរើសជំនាញសិក្សា និងអាជីព នាពេលអនាគតបានសមរម្យ។

**គោលការណ៍ណែនាំ**

គ្រូប្រឹក្សាតាមសាលារៀន ត្រូវសហការជាមួយគណៈគ្រប់គ្រងសាលារៀន ដើម្បីពិនិត្យលទ្ធភាពពេលវេលាសមស្រប ក្នុងការរៀបចំវេទិកាផ្សព្វផ្សាយកម្មវិធីត្រីវិស័យ ដែលជាកម្មវិធីទូរសព្ទឆ្លាតវៃថ្មីមួយ ដែលក្រសួងអប់រំ យុវជន និងកីឡា សហការបង្កើតឡើងជាមួយអង្គការដៃគូ។ វេទិកាផ្សព្វផ្សាយនេះ គួរត្រូវបានរៀបចំដាច់ដោយឡែកពីគ្នាតាមកម្រិតថ្នាក់នីមួយៗ និងណែនាំសិស្សឱ្យទាញយកកម្មវិធីបញ្ចូលក្នុងទូរសព្ទដៃរៀងៗខ្លួន ព្រមទាំងបង្កើតគណនីប្រើប្រាស់ តាមរយៈតំណភ្ជាប់ App Store: http://apple.co/2mtZeRj សម្រាប់ប្រព័ន្ធប្រតិបត្តការ iOS ឬ Play Store: http://bit.ly/2ntRXkC សម្រាប់ប្រព័ន្ធប្រតិបត្តិការ Android។ កន្លងមក ក្រសួងអប់រំ យុវជន និងកីឡា បានផ្ដល់កុំព្យូទ័របន្ទះ (Tablet) ដែលមានបញ្ចូលកម្មវិធីត្រីវិស័យរួចជាស្រេច ជូនដល់វិទ្យាល័យធនធានមួយចំនួន ដើម្បីបង្កលក្ខណៈងាយស្រួលដល់សិស្សដែលមិនមានទូរសព្ទឆ្លាតវៃផ្ទាល់ខ្លួន អាចមានលទ្ធភាពប្រើប្រាស់កម្មវិធីនេះបានដូចសិស្សទូទៅដែរ។ គ្រូប្រឹក្សាតាមសាលារៀន ត្រូវបែងចែកកម្មវិធី និងសិស្សជាក្រុមតូចៗ (ផ្ដល់អាទិភាពលើសិស្សស្រី) ដោយស្នើសុំកុំព្យូទ័របន្ទះ (Tablet) ពីគណៈគ្រប់គ្រងសាលារៀន មកធ្វើការណែនាំ និងផ្ដល់ជូនឱ្យសិស្សខ្លីប្រើប្រាស់កម្មវិធីត្រីវិស័យ ដើម្បីធ្វើស្វ័យវាយតម្លៃពីបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន និងស្វែងយល់ពីព័ត៌មាននានាដែលមានក្នុងកម្មវិធីនោះ។

ដើម្បីឱ្យការអនុវត្តកម្មវិធីត្រីវិស័យកាន់តែមានប្រសិទ្ធភាព គ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រង សាលារៀន ត្រូវអនុវត្តតាមសេចក្ដីណែនាំលេខ ០៩ អយក.សណន ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្ដីពីការអនុវត្តកម្មវិធីត្រីវិស័យនៅតាមគ្រឹះស្ថានមធ្យមសិក្សា។ *(ឧបសម្ព័ន្ធ៦)*

## ៥.២.៨ កម្មវិធីជំនួបមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស

**វត្ថុបំណង៖** ជំរុញ និងលើកកម្ពស់ការកសាងទំនាក់ទំនងរវាងអាណាព្យាបាលសិស្ស និងសាលារៀនឱ្យក្លាយទៅជាទម្លាប់ ដើម្បីសម្រួលដល់ដំណើរការសិក្សារបស់សិស្ស និងលើកកម្ពស់លទ្ធផលសិក្សា។

**គោលការណ៍ណែនាំ**

ជាទូទៅសាលារៀន ដើរតួនាទីសំខាន់ក្នុងការផ្ដល់ការអប់រំដល់សិស្ស។ ក្នុងនាមជាអ្នកផ្ដល់សេវាអប់រំ និងជាអ្នកសម្របសម្រួលដំណើរការសិក្សារបស់សិស្ស សាលារៀន ត្រូវផ្ដួចផ្ដើមឱ្យមានកម្មវិធីជំនួបរវាងភាគីពាក់ព័ន្ធដែលមានដូចជាសាលារៀន មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស សិស្ស សហគមន៍ អាជ្ញាធរដែនដី និងផ្នែកអន្តរាគមន៍សង្គមផ្សេងទៀត ដើម្បីដោះស្រាយបញ្ហាប្រឈម និងលើកកម្ពស់លទ្ធផលសិក្សារបស់

សិស្ស។ កិច្ចពិភាក្សាទល់មុខគ្នាអំពីការសិក្សារបស់សិស្ស គឺជាអន្តរាគមន៍ប្រកបដោយការយោគយល់ ទាន់ពេលវេលា និងមានប្រសិទ្ធភាព។

សាលារៀន ត្រូវរៀបចំឱ្យមានកម្មវិធីជំនួបមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស នៅក្នុងសាលាជាប្រចាំ ដោយអាចធ្វើឡើងយ៉ាងហោចណាស់ ០៣ដង ក្នុងមួយឆ្នាំសិក្សា (ដើមឆ្នាំសិក្សា ពាក់កណ្តាលឆ្នាំសិក្សា និងចុងឆ្នាំសិក្សា) ឬច្រើនដងជាងនេះអាស្រ័យលើលទ្ធភាព និងស្ថានភាពតម្រូវការជាក់ស្តែងរបស់សាលារៀន។ ជំនួបនេះ គឺជាយន្តការរួមគ្នាមួយរវាងសាលារៀន និងមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស ដើម្បីតាមដានការសិក្សារបស់សិស្ស ការចែករំលែកបទពិសោធអំពីការចិញ្ចឹមបីបាច់ថែរក្សាអប់រំកូនឱ្យបានល្អ ការរួមចំណែកពង្រឹងលទ្ធផលនៃការសិក្សារបស់សិស្ស ការចូលរួមវិភាគទានដល់សាលារៀនសម្រាប់ទ្រទ្រង់សកម្មភាពលើកកម្ពស់គុណភាពអប់រំ បង្កឱកាស និងការលើកកម្ពស់លទ្ធភាពបន្តការសិក្សាវែងឆ្ងាយរបស់សិស្សស្រី និងការអភិវឌ្ឍសាលារៀនជាដើម។ *(ឧបសម្ព័ន្ធ៧)*

## ៥.៣ សកម្មភាពពាក់ព័ន្ធនឹងកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា

### ៥.៣.១ ការគាំទ្រឥរិយាបថវិជ្ជមានរបស់សិស្ស (ទិវាគ្រូបង្រៀន...)

- **វត្ថុបំណង៖** បណ្តុះស្មារតីប្រកាន់ខ្ជាប់នូវសីលធម៌ និងសុជីវធម៌របស់សិស្ស និងរំឭកសាលារៀនអំពីការទទួលខុសត្រូវក្នុងការកសាងធនធានមនុស្សប្រកបដោយគុណតម្លៃ សីលធម៌ និងសុជីវធម៌ក្នុងសង្គម។
- **គោលការណ៍ណែនាំ**

ការរៀបចំកម្មវិធីអប់រំនានា (សកម្មភាពបន្ថែម Extra Activities) ក្នុងគោលបំណងអប់រំសិស្សឱ្យមានឥរិយាបថល្អ មានសីលធម៌រស់នៅល្អ មានការគោរពនិងផ្តល់តម្លៃដល់អ្នកដទៃ និងបណ្តុះស្មារតីសិស្សឱ្យចេះស្រឡាញ់ថែរក្សាអភិរក្សប្រពៃណីវប្បធម៌ បរិស្ថាន និងមានការទទួលខុសត្រូវខ្ពស់ ដើម្បីចូលរួមអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ។

សាលារៀនគួររៀបចំឱ្យមានកម្មវិធីអប់រំសីលធម៌ កម្មវិធីអប់រំផ្លូវចិត្ត កម្មវិធីសំពះអ្នកមានគុណមាតាបិតា ឬអ្នកអាណាព្យាបាល និងអ្នកគ្រូលោកគ្រូក្នុងទិវាគ្រូបង្រៀន កម្មវិធីលើកកម្ពស់ការចូលរួមក្នុងសកម្មភាពសង្គមនានាដូចជា ការថែទាំជនចាស់ជរា កាកបាទក្រហម កាយារឹទ្ធ សកម្មភាពបង្រៀនសិស្សតូចៗនៅតាមភូមិ ឬតំបន់ដាច់ស្រយាលជាដើម តាមរយៈការស្ម័គ្រចិត្ត។ កម្មវិធីនេះ គួរត្រូវបានរៀបចំយ៉ាងហោចណាស់ ១ ដង ក្នុងមួយឆ្នាំសិក្សា និងត្រូវផ្តល់ការលើកទឹកចិត្តឱ្យមានការគោរព និងផ្តល់តម្លៃដល់ស្ត្រីជាមាតាពិភពលោក។

### ៥.៣.២ ការបង្កើតក្លឹបសិក្សា

- **វត្ថុបំណង៖** ជំរុញឱ្យមានសកម្មភាពសិក្សាបន្ថែមដែលគាំទ្រដល់វិជ្ជាសម្បទា និងបំណិនសម្បទាក្រោមរូបភាពក្លឹបសិក្សានៅតាមសាលារៀន ដោយប្រើប្រាស់យន្តការសិស្សជួយសិស្ស។
- **គោលការណ៍ណែនាំ**

ការរៀបចំការបង្រៀន និងរៀន ត្រូវបានរៀបចំឡើងតាមទម្រង់ផ្សេងៗគ្នាទៅតាមលទ្ធភាព និងស្ថានភាពជាក់ស្តែង ដើម្បីឆ្លើយតបទៅនឹងរបៀបរៀន និងតម្រូវការរបស់សិស្ស ក្នុងគោលបំណងសម្រេចបាននូវ

គោលបំណងជាក់លាក់ ដោយផ្តោតលើលទ្ធផលការសិក្សារបស់សិស្សជាសំខាន់។ ចំពោះលទ្ធផលការសិក្សារបស់សិស្សមិនបានល្អ ចាំបាច់ត្រូវទទួលបានការដោះស្រាយ។ តើយើងត្រូវមានវិធីសាស្ត្របែបណាក្នុងការជួយសិស្សរៀនពូកែ? សិស្សរៀនយឺត?

ការបង្កើតក្លឹបសិក្សាជាវិធីសាស្ត្រមួយដែលអាចជួយសិស្សរៀនយឺតផង ព្រមទាំងពង្រឹង និងពង្រីកសមត្ថភាពសិស្សមធ្យម និងសិស្សពូកែផងដែរ។ ការបង្កើតក្លឹបសិក្សា ត្រូវតែកំណត់គោលបំណងឱ្យបានច្បាស់លាស់ និងត្រូវមានសមាសភាពចូលរួមគ្រប់គ្រងដឹកនាំពីគណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន គ្រូណែនាំ និងសិស្ស។ គ្រូប្រឹក្សាតាមសាលារៀន ត្រូវសហការជាមួយគណៈគ្រប់គ្រងសាលារៀន និងប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជា ដើម្បីរៀបចំបង្កើតឱ្យមានក្លឹបសិក្សាតាមមុខវិជ្ជានានាដូចជាក្លឹបភាសាបរទេស អក្សរសាស្ត្រខ្មែរ ស្ទែម ប្រវត្តិវិទ្យា អាយស៊ីធី និងក្លឹបជជែកពិភាក្សាជាដើម។ ការរៀបចំក្លឹបសិក្សានីមួយៗ គួរចាត់ឱ្យមានគ្រូណែនាំក្លឹបតាមមុខវិជ្ជាឯកទេស មានប្រធានក្លឹប សមាជិកក្លឹប (ត្រូវរៀបចំឱ្យមានសមភាពយេនឌ័រក្នុងក្លឹប និងគួរផ្តល់អាទិភាពឱ្យសិស្សស្រីជាប្រធានក្លឹប) មានសម្ភារៈ ថវិកាគាំទ្រ និងការសម្របសម្រួលឱ្យមានបន្ទប់រៀនតាមតម្រូវការចាំបាច់។ សាលារៀន អាចប្រើប្រាស់បន្ទប់បំណិនជីវិតពហុបំណង (សម្រាប់វិទ្យាល័យធនធាន) ឬបន្ទប់ណាមួយតាមលទ្ធភាពជាក់ស្តែង ដោយមានផែនការកាលវិភាគច្បាស់លាស់។ បន្ទប់បំណិនជីវិតពហុបំណង គឺជាទីកន្លែងដ៏ល្អបំផុតសម្រាប់កិច្ចដំណើរការក្លឹបនីមួយៗ ប៉ុន្តែគណៈគ្រប់គ្រងត្រូវរៀបចំបែងចែកពេលវេលាសមស្រប ចៀសវាងការប្រើប្រាស់ជាន់កម្មវិធីគ្នា។

### ៥.៣.៣ ការបង្កើតការងារគម្រោងរបស់សិស្ស

- **វត្ថុបំណង៖** លើកកម្ពស់ទម្លាប់នៃការបំពេញការងារជាក្រុម និងការសិក្សាស្រាវជ្រាវរបស់សិស្សប្រកបដោយភាពច្នៃប្រឌិតពាក់ព័ន្ធទៅនឹងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។
- **គោលការណ៍ណែនាំ**

សាលារៀន ត្រូវរៀបចំសកម្មភាពលើកទឹកចិត្តសិស្ស ឱ្យចេះស្រលាញ់ការសិក្សាស្រាវជ្រាវ និងចេះបង្កើត ក្រុមការងារដែលពូកែ។ ការរៀបចំគម្រោងបែបនេះ អាចជួយឱ្យសិស្សមានឱកាសអនុវត្តចំណេះដឹងដែលបានរៀនសូត្រពីទ្រឹស្តី ផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែង ធ្វើឱ្យសិស្សចេះដោះស្រាយបញ្ហា មានភាពច្នៃប្រឌិត បង្កើតការងារថ្មី មានមោទនភាពក្នុងការធ្វើបទបង្ហាញស្នាដៃរបស់ខ្លួន និងចេះចែករំលែកបទពិសោធ ជាមួយមិត្តភក្តិរួមសាលារៀនផងដែរ។

សាលារៀន គួរគ្រោងកញ្ចប់ថវិកាគាំទ្រសម្រាប់ផ្តល់ជូនសិស្សធ្វើការសិក្សាស្រាវជ្រាវ និងត្រូវរៀបចំបង្កើតការងារគម្រោងសម្រាប់សិស្សជាក្រុមតូចៗ ឬក្រុមធំៗ អាស្រ័យទៅលើទំហំការងារ និងថវិកាគាំទ្រ ដើម្បីឱ្យសិស្សអាចអនុវត្តគម្រោងបានល្អ។ ការរៀបចំក្រុមសិស្ស គួរបង្កលក្ខណៈឱ្យមានសមភាពយេនឌ័រក្នុងក្លឹប និងគួរផ្តល់អាទិភាពឱ្យសិស្សស្រីជាប្រធាន។ ប្រធានបទនៃគម្រោងកិច្ចការស្រាវជ្រាវនេះ ត្រូវតែទាក់ទងទៅនឹងមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។ សមិទ្ធផលសម្រេចនៃគម្រោងកម្មវិធីគម្រោងស្រាវជ្រាវរបស់ក្រុមសិស្សនេះ នឹងត្រូវយកមកផ្សព្វផ្សាយ និងតាំងបង្ហាញជាសាធារណៈ តាមរយៈព្រឹត្តិការណ៍ពិព័រណ៍សមិទ្ធផលស្នាដៃសិស្សនៅសាលារៀន ឬនៅតាមកម្មវិធីសមស្របផ្សេងៗ។

### ៥.៣.៤ ការប្រកួតប្រជែងនវានុវត្តន៍

- **វត្ថុបំណង៖** លើកកម្ពស់ការប្រឡងប្រណាំងលើការងារនវានុវត្តន៍របស់សិស្ស នៅក្នុងបរិបទនៃការអប់រំវិទ្យាសាស្ត្រ បរិស្ថាន និងការស្រាវជ្រាវអំពីបញ្ហាសង្គម។
- **គោលការណ៍ណែនាំ**

ការប្រកួតប្រជែងនវានុវត្តន៍ក្នុងសាលារៀន គឺជាការប្រឡងប្រជែងផែនការគម្រោងរបស់សិស្សគ្រប់កម្រិតថ្នាក់ ក្រោមការសម្របសម្រួលរបស់គ្រូប្រឹក្សាតាមសាលារៀន គ្រូបន្ទុកថ្នាក់ និងគណៈគ្រប់គ្រងសាលារៀន។ សាលារៀន ត្រូវលើកទឹកចិត្តឱ្យមានសមភាពយេនឌ័រ និងផ្តល់ឱកាសឱ្យសិស្សស្រីអាចចូលរួមប្រកួតប្រជែងក្នុងកម្មវិធីនេះបានដោយស្មើភាពដូចសិស្សប្រុសដែរ។ តាមរយៈកម្មវិធីប្រកួតប្រជែងនេះ សាលារៀន នឹងធ្វើការជ្រើសរើសយកគម្រោងជ័យលាភីលេខ១ ដល់លេខ៣ ដែលមានអត្ថន័យគាំទ្រដល់បរិបទអប់រំ វិទ្យាសាស្ត្រ បរិស្ថាន និងការស្រាវជ្រាវបញ្ហាសង្គមជាដើម ដើម្បីត្រៀមដាក់តាំងបង្ហាញសមិទ្ធផលស្នាដៃ ក្នុងព្រឹត្តិការណ៍ពិព័រណ៍សមិទ្ធផលស្នាដៃសិស្ស នៅសាលារៀន អមដោយការប្រគល់បណ្ណសរសើរ និងប្រាក់រង្វាន់លើកទឹកចិត្តតាមធនធានដែលសាលារៀន អាចទ្រទ្រង់បាន។

គណៈគ្រប់គ្រងសាលារៀន និងគ្រូប្រឹក្សាតាមសាលារៀន ត្រូវផ្សព្វផ្សាយអំពីកម្មវិធីប្រកួតប្រជែងនវានុវត្តន៍ក្នុងសាលារៀន ដល់សិស្សទូទៅ និងបុគ្គលិកអប់រំក្នុងសាលារៀនឱ្យបានជ្រួតជ្រាប និងជំរុញឱ្យមានការចូលរួមដាក់ពាក្យប្រកួតប្រជែងឱ្យបានគ្រប់កម្រិតថ្នាក់។ សាលារៀន ត្រូវណែនាំលក្ខខណ្ឌមួយចំនួននៃការប្រកួតប្រជែងនេះមានជាអាទិ៍៖

- សិស្សគ្រប់កម្រិតថ្នាក់ អាចរៀបចំជាក្រុមការងារ និងដាក់ពាក្យប្រកួតប្រជែងបាន
- ក្នុងមួយក្រុម ត្រូវមានសមាជិកក្នុងចន្លោះពី ៣ ទៅ ៥ រូប (សិស្សស្រី ២-៣ រូប)
- ប្រធានបទគម្រោងប្រឡងប្រជែង ត្រូវតែមានភាពទាក់ទាញ និងមានអត្ថន័យផ្តោតលើបរិបទអប់រំវិទ្យាសាស្ត្រ និងបរិស្ថាន
- ជ័យលាភីក្រុមលេខ១ ដល់លេខ៣ នឹងទទួលបានបណ្ណសរសើរ និងអមដោយប្រាក់រង្វាន់លើកទឹកចិត្តតាមលំដាប់ថ្នាក់ តាមលទ្ធភាពដែលសាលារៀនអាចទ្រទ្រង់បាន។

គណៈគ្រប់គ្រងសាលារៀន ត្រូវរៀបចំសមាសភាពគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃកិច្ចការគម្រោងរបស់ក្រុមសិស្សចំនួន ៥ រូប ដែលមានសមាសភាពចម្រុះមកពីគណៈកម្មការគ្រប់គ្រងសាលារៀនសហគមន៍ គណៈនាយក គ្រូបន្ទុកថ្នាក់ និងគ្រូប្រឹក្សាតាមសាលារៀន។

### ៥.៣.៥ ការប្រកួតប្រជែងសហគ្រិនភាព

- **វត្ថុបំណង៖** ជំរុញឱ្យមានការប្រកួតប្រជែងស្នាដៃសិស្សទាក់ទងនឹងគំនិតផ្តួចផ្តើមរឿងអាជីវកម្ម។
- **គោលការណ៍ណែនាំ**

ការប្រកួតប្រជែងសហគ្រិនភាព គឺជាការប្រឡងប្រជែងមួយដែលគ្រឹះស្ថានសិក្សាត្រូវបង្កើតឡើង ដើម្បីលើកទឹកចិត្តសិស្សឱ្យមានគំនិតសហគ្រិនភាព ដោយផ្តើមចេញពីការរៀបចំសរសេរផែនការអាជីវកម្មងាយៗ ដែលសិស្សអាចធ្វើបាន។ សាលារៀន ត្រូវលើកទឹកចិត្តឱ្យមានសមភាពយេនឌ័រ និងផ្តល់ឱកាសឱ្យសិស្សស្រីអាចចូលរួមប្រកួតប្រជែងក្នុងកម្មវិធីនេះបានដោយស្មើភាពដូចសិស្សប្រុសដែរ។ តាមរយៈកម្មវិធី

ប្រកួត ប្រជែងនេះ សាលារៀន នឹងធ្វើការជ្រើសរើសយកគម្រោងជ័យលាភីលេខ១ ដល់លេខ៣ ដែលមានលទ្ធភាព អាចអនុវត្តទៅបាន ដើម្បីត្រៀមដាក់តាំងបង្ហាញក្នុងព្រឹត្តិការណ៍ពិព័រណ៍សមិទ្ធផលស្នាដៃសិស្សនៅសាលារៀន អមដោយការជូនបណ្ណសរសើរ និងប្រាក់រង្វាន់លើកទឹកចិត្តតាមធនធានដែលសាលារៀនអាចទ្រទ្រង់បាន។

គណៈគ្រប់គ្រងសាលារៀន និងគ្រូប្រឹក្សាតាមសាលារៀន ត្រូវផ្សព្វផ្សាយអំពីកម្មវិធីប្រកួតប្រជែងសហគ្រិនភាពក្នុងសាលារៀន ដល់សិស្សទូទៅ និងបុគ្គលិកអប់រំក្នុងសាលារៀនឱ្យបានជ្រួតជ្រាប និងជំរុញឱ្យមានការចូលរួមដាក់ពាក្យប្រកួតប្រជែងឱ្យបានគ្រប់កម្រិតថ្នាក់។ សាលារៀន ត្រូវណែនាំលក្ខខណ្ឌមួយចំនួន នៃការប្រកួតប្រជែងនេះមានជាអាទិ៍៖

- សិស្សគ្រប់កម្រិតថ្នាក់ អាចរៀបចំជាក្រុមការងារ និងដាក់ពាក្យប្រកួតប្រជែងបាន
- ក្នុងមួយក្រុម ត្រូវមានសមាជិកក្នុងចន្លោះពី ៣ ទៅ ៥ រូប (សិស្សស្រី ២-៣ រូប)
- ប្រធានបទគម្រោងប្រឡងប្រជែង ត្រូវតែមានភាពទាក់ទាញ និងមានអត្ថន័យផ្តោតលើបរិបទអប់រំ វិទ្យាសាស្ត្រ និងបរិស្ថាន
- ជ័យលាភីក្រុមលេខ១ ដល់លេខ៣ នឹងទទួលបានបណ្ណសរសើរ និងអមដោយប្រាក់រង្វាន់លើកទឹកចិត្តតាមលំដាប់ថ្នាក់ តាមលទ្ធភាពដែលសាលារៀនអាចទ្រទ្រង់បាន។

គណៈគ្រប់គ្រងសាលារៀន ត្រូវរៀបចំសមាសភាពគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃកិច្ចការគម្រោងរបស់ក្រុមសិស្សចំនួន ៥ រូប ដែលមានសមាសភាពចម្រុះមកពីគណៈកម្មការគ្រប់គ្រងសាលារៀនសហគមន៍ គណៈនាយក គ្រូអប់រំសហគ្រិនភាព ឬគ្រូមុខវិជ្ជាសេដ្ឋកិច្ច និងគ្រូប្រឹក្សាតាមសាលារៀន។

## ៥.៣.៦ ការតាំងពិព័រណ៍សមិទ្ធផលស្នាដៃសិស្ស

- **វត្ថុបំណង៖** បណ្ដុះស្មារតីការងារក្រុមក្នុងកិច្ចការគម្រោង ការប្រឡងប្រជែង ការបង្កើតថ្មី ភាពច្នៃប្រឌិត ភាពម្ចាស់ការ ការចែករំលែក និងការចូលរួម របស់សិស្ស និងបុគ្គលិកអប់រំក្នុងសាលារៀន។
- **គោលការណ៍ណែនាំ**

ការតាំងពិព័រណ៍សមិទ្ធផលស្នាដៃសិស្ស ជាកម្មវិធីមួយដែលបង្កើតឡើង ដើម្បីលើកទឹកចិត្តសិស្សដែលបានចងក្រងជាក្រុមការងារតូចៗ ក្នុងគោលដៅបង្កើតគម្រោងសិក្សាស្រាវជ្រាវ (ចំណុច ៥.៣.៣) ការប្រកួតប្រជែងនវានុវត្តន៍ (ចំណុច ៥.៣.៤) និងការប្រកួតប្រជែងសហគ្រិនភាព (ចំណុច ៥.៣.៥) ខាងលើ ដែលទទួលបានជោគជ័យជាប់ជាជ័យលាភីឆ្នើមប្រចាំសាលារៀន។

កម្មវិធីនេះ គួរត្រូវបានរៀបចំឡើងមុនដំណាច់បវេសនកាលឆមាសទី១ (អាចចុងខែមីនា ឬដើមខែមេសា) ឬអាស្រ័យលើការពិភាក្សាគ្នារបស់គណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន និងអ្នកពាក់ព័ន្ធ ដោយប្រើពេលវេលា ០១ ថ្ងៃ។ ក្រុមសិស្សដែលបានចូលរួមប្រកួតប្រជែងទាំងអស់ក្នុងកម្មវិធីទាំងបីខាងលើ ត្រូវរៀបចំសមិទ្ធផលស្នាដៃរបស់ខ្លួន យកមកដាក់បង្ហាញដល់សិស្សទូទៅបានទស្សនាអមដោយការធ្វើបទបង្ហាញខ្លី ពន្យល់អំពីខ្លឹមសារ ឬដំណើរការគម្រោងរបស់ខ្លួនចែកជូនដល់អ្នកទស្សនាទូទៅ។ ក្រុមជ័យលាភីនីមួយៗ គួរផ្ដល់ឱកាសដល់សិស្សស្រីជាអ្នករង់ចាំធ្វើបទបង្ហាញជូនដល់អ្នកទស្សនា។ ឆ្លៀតក្នុងឱកាសនេះផងដែរ គណៈគ្រប់គ្រងសាលារៀន ត្រូវរៀបចំប្រកាសលទ្ធផលជ័យលាភី ជូនបណ្ណ

សរសើរ និងផ្តល់រង្វាន់លើកទឹកចិត្តដល់ក្រុមដែលទទួលបានជោគជ័យ តាមលទ្ធភាពដែលសាលារៀនអាចទ្រទ្រង់បាន (អាចទទួលវិភាគទានបន្ថែមពីសប្បុរសជន)។

## ៦. ការបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍ក្នុងមូលដ្ឋាន

### ៦.១ គោលបំណង

ការបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍ក្នុងមូលដ្ឋានរបស់ខ្លួន ពិតជាមានសារៈសំខាន់ក្នុងការរួមចំណែកជំរុញការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ឱ្យទទួលបានជោគជ័យ។ សហគមន៍ក្នុងមូលដ្ឋាន សំដៅលើក្រុមហ៊ុន សហគ្រាស អាជីវកម្ម សហគ្រិន សមាគម អង្គការក្រៅរដ្ឋាភិបាល មជ្ឈមណ្ឌលការងារ គ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតក្នុងមូលដ្ឋាន ដែលសាលារៀនត្រូវបង្កើតកិច្ចសហប្រតិបត្តិការជាមួយ។

គ្រូប្រឹក្សាតាមសាលារៀន ត្រូវមានចំណេះដឹងពាក់ព័ន្ធព័ត៌មានទីផ្សារការងារ ព័ត៌មានអំពីគ្រឹះស្ថានអប់រំបណ្តុះបណ្តាល និងកម្មវិធីសិក្សាឱ្យបានច្បាស់លាស់។ ចំណេះដឹងទាំងនេះ អាចនឹងស្វែងរកបានតាមរយៈការបង្កើតទំនាក់ទំនងដោយផ្ទាល់ជាមួយបណ្តាក្រុមហ៊ុនសហគ្រាស អាជីវកម្ម សហគ្រិន សមាគម/អង្គការក្រៅរដ្ឋាភិបាលក្នុងមូលដ្ឋានរបស់ខ្លួន និងមជ្ឈមណ្ឌលការងារ ឬតាមរយៈការសិក្សាស្រាវជ្រាវលើបណ្តាញអ៊ីនធើណេត ដើម្បីមានមូលដ្ឋានក្នុងការផ្តល់ប្រឹក្សាដល់សិស្សបានទូលំទូលាយ និងចែករំលែកព័ត៌មានចាំបាច់ដល់ពួកគេឱ្យស្វែងយល់អំពីឱកាសការងារ បទពិសោធជីវិតការងារ និងកម្មវិធីសិក្សានានា។ បន្ថែមលើនេះ វាក៏ជាចំណែកមួយនៃគំនិតផ្តួចផ្តើមបង្កើតឱ្យមានកិច្ចសហការរៀបចំកម្មវិធីទស្សនកិច្ចសិក្សា ការចុះហ្វឹកហាត់ការងាររយៈពេលខ្លី ឬពិព័រណ៍ការងារជាដើម។ ដើម្បីពង្រឹងការយល់ដឹងនូវព័ត៌មានទាំងនេះ គ្រូប្រឹក្សាតាមសាលារៀន ត្រូវរៀបចំកម្មវិធីការងាររបស់ខ្លួនក្នុងការបង្កើតទំនាក់ទំនងដោយផ្ទាល់ តាមរយៈមធ្យោបាយផ្សេងៗដែលអាចធ្វើបាន។ កិច្ចការងារនេះ អាចអនុវត្តទៅបានក៏អាស្រ័យដោយមានការជួយជ្រោមជ្រែងពីសំណាក់គណៈគ្រប់គ្រងសាលារៀនសាមីផងដែរ។

### ៦.២ ការបង្កើតបណ្តាញជាមួយសហគមន៍ក្នុងមូលដ្ឋាន

គណៈគ្រប់គ្រងសាលារៀន ដោយមានគ្រូប្រឹក្សាតាមសាលារៀនជាជំនួយការ មានទំនួលខុសត្រូវចម្បងក្នុងការបង្កើតបណ្តាញការងារជាមួយក្រុមហ៊ុនសហគ្រាស អាជីវកម្ម សហគ្រិនស្ត្រី និងគ្រឹះស្ថានផ្តល់ការអប់រំ បណ្តុះបណ្តាល សមាគម អង្គការសង្គមស៊ីវិលមូលដ្ឋាន និងមជ្ឈមណ្ឌលការងារជាដើម ដោយរៀបចំជាកិច្ចព្រមព្រៀងផ្សេងៗសំដៅជំរុញឱ្យការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ការរៀន និងបង្រៀន ប្រព្រឹត្តទៅបានដោយរលូន។ គណៈគ្រប់គ្រងសាលារៀន ទទួលបន្ទុកពិនិត្យសម្រេច និងចុះហត្ថលេខាលើកិច្ច ព្រមព្រៀងនោះជាមួយតំណាងដៃគូសហការនានា។

ការជួយគ្នាទៅវិញទៅមករវាងគ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រងសាលារៀន ក្នុងការបង្កើតបណ្តាញជាមួយដៃគូស្ថាប័នដូចបានរៀបរាប់ខាងលើ គឺជាបច្ច័យមួយដ៏សំខាន់នាំទៅរកប្រសិទ្ធភាពខ្ពស់នៃការទាញយកនូវផលប្រយោជន៍ និងការរួមចំណែកជួយជ្រោមជ្រែងជាអតិបរមាដល់ការអនុវត្តសកម្មភាពមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ការរៀន និងបង្រៀន នៅក្នុងសាលារៀន។ តាមរយៈភាពជាដៃគូនេះ គ្រូប្រឹក្សាតាមសាលារៀន អាចដាក់បញ្ចូលក្នុងផែនការសកម្មភាពការងាររបស់ខ្លួននូវការរៀបចំព្រឹត្តិការណ៍

សំខាន់ៗមួយចំនួនជាអាទិ៍៖ វេទិកាចែករំលែកបទពិសោធ វេទិកាជជែកពិភាក្សា ទស្សនកិច្ចសិក្សា ការហ្វឹកហាត់ការងារ និងពិព័រណ៍ការងារខ្នាតតូច...។ *(ឧបសម្ព័ន្ធ៨)*

## ៦.៣ យន្តការនៃការបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍ក្នុងមូលដ្ឋាន

### ៦.៣.១ កម្មវិធីជំនួបជាមួយសហគមន៍ក្នុងមូលដ្ឋាន

**វត្ថុបំណង៖** ជំរុញ និងលើកកម្ពស់ការកសាងទំនាក់ទំនងរវាងក្រុមហ៊ុនសហគ្រាស អាជីវកម្ម គ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាល សហគ្រិនស្ត្រី សមាគម អង្គការសង្គមស៊ីវិលមូលដ្ឋាន មជ្ឈមណ្ឌលការងារ និងសាលារៀនឱ្យក្លាយទៅជាទម្លាប់ ដើម្បីជំរុញប្រសិទ្ធភាពនៃដំណើរការរៀននិងបង្រៀន ព្រមទាំងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

**គោលការណ៍ណែនាំ**

ជាទូទៅ សាលារៀន ដើរតួនាទីសំខាន់ក្នុងការផ្តល់ការអប់រំដល់សិស្សឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីពួកគេអាចក្លាយខ្លួនជាពលរដ្ឋពេញលេញរបស់សង្គមជាតិ។ ក្នុងនាមជាអ្នកផ្តល់សេវាអប់រំ និងជាអ្នកសម្របសម្រួលដំណើរការសិក្សារបស់សិស្ស សាលារៀន ដោយមានគ្រូប្រឹក្សាតាមសាលារៀនជាសេនាធិការ ត្រូវផ្តួចផ្តើមឱ្យមានកម្មវិធីជំនួបរវាងសាលារៀន និងភាគីពាក់ព័ន្ធដែលមានដូចជា ក្រុមហ៊ុនសហគ្រាស អាជីវកម្ម សហគ្រិនស្ត្រី គ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាល សមាគម អង្គការសង្គមស៊ីវិលមូលដ្ឋាន និងមជ្ឈមណ្ឌលការងារ ដើម្បីជំរុញឱ្យដំណើរការរៀន និងបង្រៀន សមភាពយេនឌ័រ ការចូលរួមរបស់ស្ត្រីក្នុងវិស័យអប់រំ និងលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរ ព្រមទាំងផ្តល់ឱកាសឱ្យសិស្សស្រីសិស្សប្រុសអាចផ្សារភ្ជាប់ការសិក្សានៅសាលារៀន ទៅនឹងពិភពការងារជាក់ស្តែងតាមរូបភាពផ្សេងៗនៃកិច្ចសហការដែលនឹងត្រូវបង្កើតឡើង។

សាលារៀន ត្រូវរៀបចំឱ្យមានកម្មវិធីជំនួបជាមួយភាគីពាក់ព័ន្ធនេះ នៅក្នុងសាលារៀនជាប្រចាំ ដោយអាចធ្វើឡើងយ៉ាងហោចណាស់ ០២ ដង ក្នុងមួយឆ្នាំសិក្សា (ដើមឆ្នាំសិក្សា និងពាក់កណ្តាលឆ្នាំសិក្សា) ឬ ១ ដង/ត្រីមាស ដើម្បីពិនិត្យលទ្ធភាពរួមគ្នាក្នុងការបង្កើតកិច្ចសហការរៀបចំកម្មវិធីការងារសំខាន់ៗដូចដែលនឹងមានបង្ហាញក្នុងចំណុចបន្តបន្ទាប់ខាងក្រោមនេះស្រាប់។ ដើម្បីជំរុញកិច្ចការនេះឱ្យមានប្រសិទ្ធភាព គណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន ត្រូវចាត់ចែងរៀបចំកំណត់កាលបរិច្ឆេទ និងលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់គ្រប់ភាគីពាក់ព័ន្ធ ដោយមានគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាអ្នកដឹកនាំកិច្ចប្រជុំ (បើអាចទៅរួច)។ តាមរយៈកិច្ចប្រជុំនេះ សំឡេងនៃការចូលរួមរបស់ភាគីពាក់ព័ន្ធខាងលើ និងក្លាយជាធាតុចូលដ៏សំខាន់ក្នុងការជំរុញការអភិវឌ្ឍសាលារៀន និងការរៀនសូត្ររបស់សិស្ស ហើយក៏ជាផ្នែកមួយនៃការបង្កើនប្រសិទ្ធភាពនៃការងារបណ្តាញរបស់គ្រូប្រឹក្សាតាមសាលារៀនផងដែរ។ *(ឧបសម្ព័ន្ធ៩)*

### ៦.៣.២ វេទិកាចែករំលែកបទពិសោធដោយវាគ្មិន

**វត្ថុបំណង៖** ផ្តល់ឱ្យសិស្សនូវឱកាសក្នុងការជួបប្រាស្រ័យទាក់ទង និងសន្ទនាដោយផ្ទាល់ជាមួយអ្នកដែលមានបទពិសោធក្នុងការសិក្សា ការបំពេញការងារ ការដឹកនាំអាជីវកម្ម ដើម្បីពួកគេបានជាទុនក្នុងការត្រៀមខ្លួនបង្កើតឱកាស និងជម្រើសផ្ទាល់ខ្លួននាពេលអនាគតបានសមរម្យ។

- គោលការណ៍ណែនាំ

តាមរយៈកម្មវិធីការងារដែលបានគ្រោងទុក និងលទ្ធផលនៃកិច្ចប្រជុំ (ចំណុច ៦.៤.១ ខាងលើ) គ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រងសាលារៀន ត្រូវរៀបចំវេទិកាចែករំលែកបទពិសោធ ដោយអញ្ជើញវាគ្មិនជាតំណាងមកពីមជ្ឈមណ្ឌលការងារ ឬក្រុមហ៊ុនសហគ្រាស ឬសហគ្រិនស្ត្រីជោគជ័យ ឬអតីតសិស្សឆ្នើមប្រចាំសាលាជាដើម (ស្នើឱ្យផ្តោតលើវត្តមានស្ត្រីចូលរួម) មកធ្វើបទបង្ហាញជូនដល់ក្រុមសិស្សគោលដៅ (គួរតែថ្នាក់ទី១១ ឬ ថ្នាក់ទី១២) ដោយប្រើរយៈពេល ០១ ព្រឹក ឬ ០១ រសៀល។ ប្រធានបទនៃការចែករំលែកនេះ គួរត្រូវបានផ្តោតជាសំខាន់លើ ព័ត៌មានអប់រំ ព័ត៌មានទីផ្សារការងារ និងព័ត៌មានអំពីអាជីពការងារ ភាពជោគជ័យរបស់ស្ត្រីលើវិស័យការងារផ្សេងៗ ជូនដល់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលវាឆ្លើយតបនឹងស្លោកដែលជាគោលដៅចុងក្រោយនៃការអប់រំនោះគឺ រៀនដើម្បីធ្វើការ ធ្វើការដើម្បីរកប្រាក់ រកប្រាក់ដើម្បីរស់ រស់ដើម្បីបម្រើ។ ការចែករំលែកព័ត៌មានក្នុងវេទិកានេះ នឹងផ្តល់ឱកាសឱ្យសិស្សទូទៅ ពិសេសសិស្សស្រី មើលឃើញនូវរូបភាពការងារ លក្ខខណ្ឌនិច្ច័យសម្រាប់ការងារ លក្ខខណ្ឌគាំទ្រដល់វិស័យការងារ សក្តានុពលផ្ទាល់ខ្លួនចំពោះការងារ គុណតម្លៃ និងលទ្ធភាពរបស់ស្ត្រីក្នុងការបំពេញការងារបានស្មើមុខនឹងបុរសដែរ។

គ្រូប្រឹក្សាតាមសាលារៀន ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលដំណើរការរៀបចំ និងអញ្ជើញវាគ្មិនជំនាញ ឱ្យជួយធ្វើបទបង្ហាញដើម្បីចែករំលែកបទពិសោធ លើកទឹកចិត្ត និងគាំទ្រផ្នែកស្មារតីដល់សិស្ស។ កម្មវិធីនេះ ត្រូវបានលើកទឹកចិត្តឱ្យមានការចូលរួមពីសំណាក់វាគ្មិនជាស្ត្រី។

### ៦.៣.៣ វេទិកាជជែកពិភាក្សា (វាគ្មិនច្រើន)

- **វត្ថុបំណង៖** ផ្តល់ឱ្យសិស្សនូវឱកាសក្នុងការជួបប្រាស្រ័យទាក់ទង និងសន្ទនាដោយផ្ទាល់ជាមួយអ្នកដែលមានបទពិសោធក្នុងការសិក្សា ការបំពេញការងារ ការដឹកនាំអាជីវកម្ម មកពីប្រភពផ្សេងៗគ្នា ដើម្បីពង្រីកការយល់ដឹងរបស់សិស្សអំពីពិភពការងារ ការជ្រើសរើសផ្លូវសិក្សា និងអាជីពបានកាន់តែទូលំទូលាយ។

- គោលការណ៍ណែនាំ

តាមរយៈកម្មវិធីការងារដែលបានគ្រោងទុក និងលទ្ធផលនៃកិច្ចប្រជុំ (ចំណុច ៦.៤.១ ខាងលើ) គ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រងសាលារៀន ត្រូវរៀបចំវេទិកាជជែកពិភាក្សា ដោយអញ្ជើញវាគ្មិនមកពីស្ថាប័នផ្សេងគ្នាចំនួន ០៣ ឬ ០៤ រូប (លើកទឹកចិត្តឱ្យមានវាគ្មិនជាស្ត្រីចូលរួម) មកបកស្រាយលើប្រធានបទជាក់លាក់ណាមួយ មកចែករំលែកជូនដល់ក្រុមសិស្ស (គួរតែថ្នាក់ទី១១ ឬ ថ្នាក់ទី១២) ក្នុងរយៈពេល ០១ ព្រឹក ឬ ០១ រសៀល។ ការរៀបចំវេទិកាក្នុងទម្រង់ជា Panel Discussion នេះ តម្រូវឱ្យមានអ្នកសម្របសម្រួលកម្មវិធីម្នាក់ (អាចជាគ្រូប្រឹក្សាតាមសាលារៀន)។ ប្រធានបទនៃការចែករំលែកនេះ គួរត្រូវបានផ្តោតជាសំខាន់លើ ព័ត៌មានអប់រំ ព័ត៌មានទីផ្សារការងារ និងព័ត៌មានអំពីអាជីពការងារ ភាពជោគជ័យរបស់ស្ត្រីលើវិស័យការងារផ្សេងៗ ជូនដល់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ។ ការចែករំលែកព័ត៌មានក្នុងវេទិកានេះ នឹងផ្តល់ឱកាសបន្ថែមទៀតឱ្យសិស្សទូទៅ ពិសេសសិស្សស្រី មើលឃើញនូវរូបភាពការងារ លក្ខខណ្ឌនិច្ច័យសម្រាប់ការងារ លក្ខខណ្ឌគាំទ្រដល់វិស័យការងារ សក្តានុពលផ្ទាល់ខ្លួនចំពោះការងារ គុណតម្លៃ និងលទ្ធភាពរបស់ស្ត្រីក្នុងការបំពេញការងារបានស្មើមុខនឹងបុរសដែរ។

### ៦.៣.៤ ទស្សនកិច្ចសិក្សា

- **វត្ថុបំណង៖** លើកទឹកចិត្តសិស្សឱ្យផ្សារភ្ជាប់ចំណាប់អារម្មណ៍ការងារទៅនឹងពិភពការងារជាក់ស្តែង តាមរយៈការចុះទស្សនកិច្ចសិក្សា នៅតាមគ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាល ក្រុមហ៊ុនសហគ្រាស អាជីវកម្មក្នុងមូលដ្ឋាន ឬមជ្ឈមណ្ឌលការងារ។
- **គោលការណ៍ណែនាំ**

តាមរយៈកម្មវិធីការងារដែលបានគ្រោងទុក និងលទ្ធផលនៃកិច្ចប្រជុំ (ចំណុច ៦.៤.១ ខាងលើ) គ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រងសាលារៀន ក្នុងភាពជាដៃគូសហការ ដែលសំដៅដល់កិច្ចសហប្រតិបត្តិការរវាងសាលារៀន និងវិស័យឯកជនដូចជា ធនាគារ ផ្សារទំនើប បណ្ណាគារ សហគ្រាសខ្នាតមធ្យម និងសហគ្រាសខ្នាតតូចជាដើម។ ការផ្តល់ឱកាសឱ្យសិស្សថ្នាក់ទី១២ បានចុះទស្សនកិច្ចសិក្សា នៅតាមធនាគារ ផ្សារទំនើប បណ្ណាគារ ក្រុមហ៊ុនសហគ្រាសក្នុងមូលដ្ឋាន អាចជួយសិស្សឱ្យមើលឃើញអំពីសង្វាក់ផលិតកម្មជាក់ស្តែងនៃការបំពេញការងារ ដែលជាចំណែកគាំទ្រយ៉ាងសំខាន់ដល់សិស្ស ក្នុងការទាញចំណាប់អារម្មណ៍សិស្សឱ្យសាកល្បងបន្ស៊ីចំណង់ចំណូលចិត្ត ផែនការសិក្សាជំនាញ និងអាជីពនាថ្ងៃអនាគត ទៅនឹងពិភពការងារដែលពួកគេបានឃើញ។ ការណ៍នេះ នឹងជួយសិស្សឱ្យកាន់តែស្រឡាញ់ចូលចិត្តការសិក្សា និងមានឆន្ទៈពុះពាររៀនសូត្រ ដើម្បីចាប់យកជំនាញសមស្របតាមចំណង់ចំណូលចិត្តរបស់ខ្លួននាពេលអនាគត។ សាលារៀនត្រូវស្វែងរកដៃគូវិស័យឯកជន ដើម្បីឱ្យសិស្សបានចុះទស្សនកិច្ចសិក្សា និងរៀបចំចាត់ចែងឱ្យមានកិច្ចព្រមព្រៀងរយៈពេលខ្លី ឬមធ្យមរវាងសាលារៀន ជាមួយនឹងវិស័យឯកជននោះ។

គណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន និងលោកគ្រូ អ្នកគ្រូទាំងអស់ ត្រូវសហការគ្នាកៀរគរវិស័យឯកជន ដែលជាគោលដៅបណ្តាញសម្រាប់សិស្សថ្នាក់ទី១២ បានចុះទស្សនកិច្ចសិក្សា (រយៈពេល ១ ព្រឹក ឬ ១ រសៀល ឬ ១ ថ្ងៃ)។ គណៈគ្រប់គ្រងសាលារៀន និងគ្រូប្រឹក្សាតាមសាលារៀន ត្រូវចចារ និងរៀបចំឱ្យមានជាកិច្ចព្រមព្រៀងរវាងសាលារៀន និងវិស័យឯកជននានា ដោយមានចែងអំពីចំនួនសិស្សត្រូវចូលរួមម្តងៗតាមភាពជាក់ស្តែង។ យន្តការជ្រើសរើសសិស្សចុះទស្សនកិច្ចសិក្សា ត្រូវរៀបចំឡើងដោយគណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន និងតំណាងវិស័យឯកជន។ សាលារៀន ត្រូវរៀបចំក្រុមសិស្សចុះទស្សនកិច្ចសិក្សាផ្អែកលើគោលការណ៍សមភាពយេនឌ័រ ដោយផ្តល់ឱកាស និងបង្កលទ្ធភាពដល់សិស្សស្រី ដើម្បីឱ្យពួកគេអាចចូលរួមការចុះទស្សនកិច្ចសិក្សាដូចសិស្សប្រុសដែរ។ *(ឧបសម្ព័ន្ធ១០)*

### ៦.៣.៥ ការសង្កេតការងារ

- **វត្ថុបំណង៖** លើកទឹកចិត្តសិស្សឱ្យផ្សារភ្ជាប់ចំណាប់អារម្មណ៍ការងារទៅនឹងពិភពការងារជាក់ស្តែង តាមរយៈការហ្វឹកហាត់ការងាររយៈពេលខ្លី នៅតាមគ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាល ក្រុមហ៊ុនសហគ្រាស អាជីវកម្មក្នុងមូលដ្ឋាន ឬមជ្ឈមណ្ឌលការងារ។
- **គោលការណ៍ណែនាំ**

តាមរយៈកម្មវិធីការងារដែលបានគ្រោងទុក និងលទ្ធផលនៃកិច្ចប្រជុំ (ចំណុច ៦.៤.១ ខាងលើ) គ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រងសាលារៀន ក្នុងភាពជាដៃគូសហការ សំដៅដល់កិច្ចសហប្រតិបត្តិការរវាងសាលារៀន និងវិស័យឯកជន ដូចជាធនាគារ ផ្សារទំនើប បណ្ណាគារ សហគ្រាសខ្នាតមធ្យម សហ

គ្រាសខ្នាតតូច ឬមជ្ឈមណ្ឌលការងារជាដើម។ ការផ្តល់ឱកាសឱ្យសិស្សថ្នាក់ទី ១១ បានហាត់ការរយៈពេលខ្លី (០៣ថ្ងៃ ទៅ ០៥ថ្ងៃ) នៅតាមធនាគារ ផ្សារទំនើប បណ្ណាគារ ឬក្រុមហ៊ុនសហគ្រាសក្នុងមូលដ្ឋាននេះ អាចជួយសិស្សឱ្យមើលឃើញអំពីចំណង់ចំណូលចិត្ត ជំនាញ ភាពខ្លាំង និងចំណុចត្រូវពង្រឹងខ្លួនឯងចំពោះប្រភេទការងារដែលខ្លួនចូលចិត្ត។ ការណ៍នេះ នឹងជួយសិស្សឱ្យកាន់តែស្រឡាញ់ចូលចិត្តការសិក្សា និងមានឆន្ទៈពុះពាររៀនសូត្រ ដើម្បីចាប់យកជំនាញសមស្របតាមចំណង់ចំណូលចិត្តរបស់ខ្លួន នាពេលអនាគត។ សាលារៀនត្រូវស្វែងរកដៃគូសហការ ដើម្បីឱ្យសិស្សបានចុះហ្វឹកហាត់ការងារ និងចាត់ចែងឱ្យមានកិច្ចព្រមព្រៀងរយៈពេលមធ្យមរវាងសាលារៀន និងស្ថាប័ននោះ។

គណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន និងលោកគ្រូ អ្នកគ្រូទាំងអស់ ត្រូវសហការគ្នាកៀរគរវិស័យឯកជន ដែលជាគោលដៅបណ្តាញសម្រាប់សិស្សថ្នាក់ទី១១ បានចុះហ្វឹកហាត់ការងាររយៈពេលខ្លី (៣ ថ្ងៃ ទៅ ៥ ថ្ងៃ)។ គណៈគ្រប់គ្រងសាលារៀន និងគ្រូប្រឹក្សាតាមសាលារៀន ត្រូវចចារ និងរៀបចំឱ្យមានជាកិច្ចព្រមព្រៀងរវាងសាលារៀន និងដៃគូសហការនានា ដោយមានចែងអំពីចំនួនសិស្ស (មិនលើសពី ៥ រូប) លក្ខខណ្ឌជ្រើសរើសសិស្ស និងរយៈពេលនៃការហ្វឹកហាត់ការងាររបស់សិស្ស ទៅតាមស្ថានភាពជាក់ស្តែង។ យន្តការជ្រើសរើសសិស្សហ្វឹកហាត់ការងារ ត្រូវរៀបចំឡើងដោយគណៈគ្រប់គ្រងសាលារៀន គ្រូប្រឹក្សាតាមសាលារៀន និងតំណាងស្ថាប័នដែលទទួលជាក់ស្តែង។ សាលារៀន ត្រូវរៀបចំក្រុមសិស្សចុះហាត់ការ ផ្អែកលើគោលការណ៍សមភាពយេនឌ័រ ដោយផ្តល់ឱកាស និងបង្កលទ្ធភាពដល់សិស្សស្រី ដើម្បីឱ្យពួកគេអាចចូលរួមការហ្វឹកហាត់ការងារបានដូចសិស្សប្រុសដែរ។ សិស្សហ្វឹកហាត់ការងារ អាចនឹងមានថវិកាឧបត្ថម្ភមួយចំនួនសម្រាប់ហូបចុក ទៅតាមលទ្ធភាពនៃការចចារដូចដែលមានបញ្ជាក់ក្នុងកិច្ចព្រមព្រៀង។ *(ឧបសម្ព័ន្ធ១១-១២)*

## ៦.៣.៦ ការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ការងារខ្នាតតូច

- **វត្ថុបំណង៖** ជំរុញ និងលើកទឹកចិត្តសិស្សឱ្យចូលរួមទទួលយកបទពិសោធ យល់ដឹងពីព័ត៌មានទីផ្សារការងារក្នុងមូលដ្ឋាន និងត្រៀមលក្ខណៈសម្បត្តិផ្ទាល់ខ្លួនបានល្អ ដើម្បីឈោងចាប់ឱកាសការងារ។
- **គោលការណ៍ណែនាំ**

តាមរយៈកម្មវិធីការងារដែលបានគ្រោងទុក និងលទ្ធផលនៃកិច្ចប្រជុំ (ចំណុច ៦.៤.១ ខាងលើ) គ្រូប្រឹក្សាតាមសាលារៀន និងគណៈគ្រប់គ្រងសាលារៀន ត្រូវពិនិត្យលទ្ធភាពពេលវេលានៅចុងឆ្នាំសិក្សា ដោយធ្វើការសហការជាមួយបណ្តាក្រុមហ៊ុនសហគ្រាស អាជីវកម្ម សហគ្រិនស្ត្រី បណ្ណាគារ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សិប្បកម្មក្នុងមូលដ្ឋាន និងមជ្ឈមណ្ឌលការងារ ដើម្បីរៀបចំបង្កើតព្រឹត្តិការណ៍ពិព័រណ៍ការងារខ្នាតតូចមួយនៅសាលារៀន។ ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលបានចូលរួម នឹងតម្រូវឱ្យដាក់តាំងបង្ហាញនូវផលិតផលស្នាដៃ អាជីវកម្ម បញ្ជីតម្រូវការជំនាញ និងកម្លាំងពលកម្ម ដោយបរិយាយអំពីលក្ខខណ្ឌចូលបម្រើការ តួនាទីភារកិច្ចក្នុងមុខតំណែងនីមួយៗ... ព្រមជាមួយការរៀបចំឱ្យមានអ្នកចាំធ្វើបទបង្ហាញខ្លីជូនអ្នកទស្សនាស្តង់ (លើកទឹកចិត្តដល់ស្ត្រីជាអ្នកចាំធ្វើបទបង្ហាញ) ក្នុងរយៈពេល ០១ ថ្ងៃពេញ។ ការរៀបចំនេះ ទាមទារនូវកិច្ចសហការស្អិតរមួតជាមួយមជ្ឈមណ្ឌលការងាររាជធានី ខេត្ត ដែលជាភ្នាក់ងារសាធារណៈផ្តល់សេវាការងារ និង ព័ត៌មានទីផ្សារការងារ។ ជាមួយគ្នានេះ សាលារៀនត្រូវសម្របសម្រួលរៀបចំទីតាំង និងបញ្ជូរសមរម្យតាមលទ្ធភាពដែលអាចធ្វើបាន ព្រមទាំងចាត់ចែងសិស្សចូលរួមទស្សនា ដោយផ្តោតជាសំខាន់លើក្រុម

សិស្សមធ្យមសិក្សាទុតិយភូមិ។ កម្មវិធីនេះ នឹងជួយផ្តល់មូលដ្ឋានបន្ថែមដល់សិស្សក្នុងការធ្វើស្វ័យសម្រេចចិត្តជ្រើសរើស និងកំណត់គោលដៅ ការអប់រំបន្ត និងអាជីពរបស់ខ្លួនបានកាន់តែប្រសើរថែមទៀត។

ដើម្បីជាការលើកទឹកចិត្តដល់ស្ថាប័នពាក់ព័ន្ធដែលបានចូលរួមដាក់បញ្ចូលតាំងពិព័រណ៍នេះ សាលារៀនគួររៀបចំលិខិតថ្លែងអំណរគុណដោយមានចុះហត្ថលេខា និងប្រថាប់ត្រារបស់អង្គភាពត្រឹមត្រូវផ្តល់ជូន នៅចុងបញ្ចប់កម្មវិធី។

## ៧. ការពិនិត្យតាមដាន និងវាយតម្លៃ

ការពិនិត្យតាមដាន និងវាយតម្លៃ គឺជាសកម្មភាពមួយចាំបាច់ ក្នុងការពិនិត្យឡើងវិញនូវការអនុវត្តកម្មវិធីការងារមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដែលសាលារៀនបានកំណត់នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ខ្លួន។ សកម្មភាពនេះ ជាការផ្តល់ឱកាសដល់អ្នកអនុវត្តបានជួបពិភាក្សា ដោយផ្ទាល់ជាមួយមន្ត្រីជំនាញ និងអ្នកពាក់ព័ន្ធ លើការងារគ្រប់គ្រង និងការងារផ្នែកបច្ចេកទេស ដើម្បីរកឱ្យឃើញនូវចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងដំណោះស្រាយ សម្រាប់អនុវត្តនាឆ្នាំសិក្សាក្រោយៗប្រកបដោយប្រសិទ្ធភាព។

យន្តការនៃការចុះពិនិត្យតាមដាន និងវាយតម្លៃ នឹងត្រូវធ្វើឡើងដោយការិយាល័យជំនាញ នៃមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តសាមី និងបុគ្គលិកអប់រំនៃនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ទៅតាមកម្មវិធីការងារជាក់ស្តែង។

## ៨. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីដាក់ឱ្យដំណើរការកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងនិងការផ្តល់ប្រឹក្សា នៅតាមគ្រឹះស្ថានមធ្យមសិក្សាក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា ឥរិយាបទសិក្សារបស់សិស្សានុសិស្សនឹងមានការផ្លាស់ប្តូរ ដោយពួកគេនឹងមានភាពច្នៃប្រឌិតច្រើន ការគិតបែបវិជ្ជមាន ស្គាល់ខ្លួនឯងកាន់តែច្បាស់ មានគោលដៅជាក់លាក់ក្នុងជីវិត ពិសេសមានមូលដ្ឋានរឹងមាំក្នុងការសម្រេចចិត្តជ្រើសរើសមុខជំនាញសិក្សា និងអាជីព សមស្របទៅនឹងឧបនិស្ស័យ ចំណង់ចំណូលចិត្ត ព្រមទាំងទទួលបានព័ត៌មានបន្ថែមពាក់ព័ន្ធការបណ្តុះបណ្តាលជំនាញ និងព័ត៌មានទីផ្សារការងារជាដើម។

បន្ថែមពីនេះ លោកគ្រូអ្នកគ្រូទទួលបន្ទុកអនុវត្តកម្មវិធីនេះ នឹងមានទម្លាប់ដាក់ចេញនូវកម្មវិធីលើកកម្ពស់ការសិក្សារបស់សិស្សដូចជា ការតម្រង់ទិសការសិក្សានិងវិជ្ជាជីវៈ ការអភិវឌ្ឍជំនាញទន់ ដូចជាជំនាញទំនាក់ទំនង ជំនាញការងារក្រុម ជំនាញដោះស្រាយបញ្ហា ជំនាញធ្វើបទបង្ហាញ។

សាលារៀន នឹងចាប់ផ្តើមបង្កើតទម្លាប់រៀបចំឱ្យមានកម្មវិធីប្រកួតប្រជែងស្នាដៃច្នៃប្រឌិតរបស់សិស្ស និងកម្មវិធីជំនួប ឬព្រឹត្តិការណ៍សំខាន់ៗដទៃទៀត ដូចជាជំនួបរវាងសាលារៀន និងសហគមន៍ សាលារៀន និងមាតាបិតាសិស្ស សាលារៀនជាមួយនឹងសហគ្រាសខ្នាតតូច និងមធ្យម។

លទ្ធផលជាវិជ្ជមានអំពីកម្មវិធីនេះ នឹងអាចបំពេញបាននូវតម្រូវការទីផ្សារពេលកម្មនាពេលអនាគត និងអាចចូលរួមឆ្លើយតបនឹងចក្ខុវិស័យក្នុងការអភិវឌ្ឍប្រទេសរបស់រាជរដ្ឋាភិបាលនាឆ្នាំ ២០៣០ខាងមុខ។

# ឧបសម្ព័ន្ធ១ គំរូផែនការសកម្មភាព និងថវិកាគាំទ្រ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលក្រុង ស្រុក ខណ្ឌ..................**
**ការិយាល័យអប់រំ យុវជន និងកីឡា**
**វិទ្យាល័យ.......................................**

## គំរូផែនការសកម្មភាព និងថវិកាគាំទ្រ

| ល.រ | បរិយាយសកម្មភាព | តម្រូវការថវិកា (ឯកតាគិតរៀល) | ក្របខណ្ឌពេលវេលា | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា |
| ៥.១ ការរៀបចំផែនការ និងថវិកាគាំទ្រ | | | | | | | | | | | | | | |
| ៥.២ ការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា | | | | | | | | | | | | | | |
| ១ | ៥.២.១ ការតម្រង់ទិសមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាក្នុងកម្មវិធីបវេសនកាល | | | | | | | | | | | | | |
| ២ | ៥.២.២ ការតម្រង់ទិសសិស្សក្នុងដំណាក់កាលឆ្លងភូមិសិក្សា | | | | | | | | | | | | | |
| ៣ | ៥.២.៣ ការតម្រង់ទិសសិស្សថ្នាក់ទី១២ | | | | | | | | | | | | | |
| ៤ | ៥.២.៤ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់សម្រាប់មធ្យមសិក្សាបឋមភូមិ | | | | | | | | | | | | | |
| ៥ | ៥.២.៥ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់សម្រាប់មធ្យមសិក្សាទុតិយភូមិ | | | | | | | | | | | | | |
| ៦ | ៥.២.៦ ការផ្តល់ប្រឹក្សាទល់មុខ | | | | | | | | | | | | | |
| ៧ | ៥.២.៧ ការប្រើប្រាស់កម្មវិធីត្រីវិស័យ | | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៨ | ៥.២.៨ កម្មវិធីជំនួបមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស | | | | | | | | | | | | | |
| ៥.៣ សកម្មភាពពាក់ព័ន្ធនឹងកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា | | | | | | | | | | | | | | |
| ៩ | ៥.៣.១ ការគាំទ្រផែនការអាជីពរបស់សិស្ស ( ទិវាគ្រូបង្រៀន ) | | | | | | | | | | | | | |
| ១០ | ៥.៣.២ ការបង្កើតក្លឹបសិក្សា | | | | | | | | | | | | | |
| ១១ | ៥.៣.៣ ការបង្កើតការងារគម្រោងរបស់សិស្ស | | | | | | | | | | | | | |
| ១២ | ៥.៣.៤ ការប្រកួតប្រជែងនវានុវត្តន៍ | | | | | | | | | | | | | |
| ១៣ | ៥.៣.៥ ការប្រកួតប្រជែងសហគ្រិនភាព | | | | | | | | | | | | | |
| ១៤ | ៥.៣.៦ ការតាំងពិព័រណ៍សមិទ្ធផលស្នាដៃសិស្ស | | | | | | | | | | | | | |
| ៦.៤ យន្តការនៃការបង្កើតភាពជាដៃគូរវាងសាលារៀន និងសហគមន៍ក្នុងមូលដ្ឋាន | | | | | | | | | | | | | | |
| ១៥ | ៦.៤.១ កម្មវិធីជំនួបជាមួយសហគមន៍ក្នុងមូលដ្ឋាន | | | | | | | | | | | | | |
| ១៦ | ៦.៤.២ វេទិកាចែករំលែកបទពិសោធដោយវាគ្មិន | | | | | | | | | | | | | |
| ១៧ | ៦.៤.៣ វេទិកាជជែកពិភាក្សា (វាគ្មិនច្រើន) | | | | | | | | | | | | | |
| ១៨ | ៦.៤.៤ ទស្សនកិច្ចសិក្សា | | | | | | | | | | | | | |
| ១៩ | ៦.៤.៥ ការហ្វឹកហាត់ការងារ | | | | | | | | | | | | | |
| ២០ | ៦.៤.៦ ការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ការងារខ្នាតតូច | | | | | | | | | | | | | |

ថ្ងៃ...................... ខែ........... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

.................ថ្ងៃទី........... ខែ..............ឆ្នាំ២០២២

**គ្រូប្រឹក្សាតាមសាលារៀន**

**បានឃើញ និងឯកភាព**

**នាយក**

## ឧបសម្ព័ន្ធ២ គំរូគម្រោងចំណាយថវិកាលម្អិតតាមសកម្មភាពនីមួយៗ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលក្រុង ស្រុក ខណ្ឌ**……………….
**ការិយាល័យអប់រំ យុវជន និងកីឡា**
**វិទ្យាល័យ**…………………………………

### គំរូគម្រោងចំណាយថវិកាលម្អិតតាមសកម្មភាពនីមួយៗ

| ល.រ | បរិយាយមុខចំណាយ | ឯកតា | តម្លៃ/ឯកតា | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ៥.១ ការរៀបចំផែនការ និងថវិកាគាំទ្រ | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.២.១ ការតម្រង់ទិសមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ក្នុងកម្មវិធីបរេសនកាល | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.២.២ ការតម្រង់ទិសសិស្សក្នុងដំណាក់កាលឆ្លងឆ្នាំសិក្សា | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.២.៣ ការតម្រង់ទិសសិស្សថ្នាក់ទី១២ | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.២.៤ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់សម្រាប់មធ្យមសិក្សាបឋមភូមិ | | | | | |
| | | | | | |
| | | | | | |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| ៥.២.៥ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់សម្រាប់មធ្យមសិក្សាទុតិយភូមិ | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.២.៦ ការផ្តល់ប្រឹក្សាទល់មុខ | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.២.៧ ការប្រើប្រាស់កម្មវិធីត្រីវិស័យ | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.២.៨ កម្មវិធីជំនួបមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.៣.១ ការគាំទ្រឥរិយាបថវិជ្ជមានរបស់សិស្ស (ទិវាគ្រូបង្រៀន) | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.៣.២ ការបង្កើតក្លឹបសិក្សា | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.៣.៣ ការបង្កើតការងារគម្រោងរបស់សិស្ស | | | | | |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| ៥.៣.៤ ការប្រកួតប្រជែងនវានុវត្តន៍ | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.៣.៥ ការប្រកួតប្រជែងសហគ្រិនភាព | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៥.៣.៦ ការតាំងពិព័រណ៍សមិទ្ធផលស្នាដៃសិស្ស | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៦.៤.១ កម្មវិធីជំនួបជាមួយសហគមន៍ក្នុងមូលដ្ឋាន | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៦.៤.២ វេទិកាចែករំលែកបទពិសោធដោយវាគ្មិន | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៦.៤.៣ វេទិកាជជែកពិភាក្សា (វាគ្មិនច្រើន) | | | | | |
| | | | | | |
| | | | | | |
| | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៦.៤.៤ ទស្សនកិច្ចសិក្សា | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៦.៤.៥ ការហ្វឹកហាត់ការងារ | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ៦.៤.៦ ការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ការងារខ្នាតតូច | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ថ្ងៃ........................ ខែ............ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

..................ថ្ងៃទី............ ខែ...............ឆ្នាំ២០២២

**គ្រូប្រឹក្សាតាមសាលារៀន**

**បានឃើញ និងឯកភាព**

**នាយក**

**ឧបសម្ព័ន្ធ៣ របាយការណ៍ប្រចាំសប្តាហ៍នៃការអនុវត្តសេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលក្រុង ស្រុក ខណ្ឌ**.................
**ការិយាល័យអប់រំ យុវជន និងកីឡា**
**វិទ្យាល័យ**.......................................

**របាយការណ៍ប្រចាំសប្តាហ៍នៃការអនុវត្តសេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់**

(ចាប់ពីថ្ងៃទី......... ដល់ថ្ងៃទី......... ខែ.............. ឆ្នាំ២០២១)

១. លទ្ធផលសម្រេចបាន

| ល.រ | កាលបរិច្ឆេទ | ថ្នាក់ទី | ចំនួនសិស្ស | | ចំណងជើងមេរៀន | រយៈពេលបង្រៀន |
|---|---|---|---|---|---|---|
| | | | សរុប | ស្រី | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

២. យោបល់/សំណូមពរ

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

ថ្ងៃ......................... ខែ............ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

..................ថ្ងៃទី............ ខែ...............ឆ្នាំ២០២២

**បានឃើញ និងឯកភាព** **អ្នកធ្វើរបាយការណ៍**

**នាយក**

# ឧបសម្ព័ន្ធ៤ ដំណាក់កាលនៃការផ្តល់ប្រឹក្សាទល់មុខ

## ១. ដំណាក់កាលរៀបចំ (មុនពេលសិស្សចូលមកទទួលការប្រឹក្សាយោបល់)

- ប្រសិនបើគ្រូប្រឹក្សាតាមសាលារៀន ធ្លាប់បានស្គាល់ប្រវត្តិរបស់សិស្ស គួរតែរំឭកខ្លួនឯងឡើងវិញនូវចំណេះដឹង ឬព័ត៌មានដែលបានដឹង ឬចងចាំពីមុនមក
- ប្រសិនបើដឹងអំពីប្រធានបទសម្រាប់ផ្តល់ប្រឹក្សាយោបល់ (ឧទាហរណ៍ *បញ្ហាលំបាកក្នុងការសិក្សា*) គួរព្យាយាមប្រមូលព័ត៌មានពាក់ព័ន្ធពីគ្រូមុខវិជ្ជាផ្សេងៗដែលគេរៀនជាមួយ ឬស្រាវជ្រាវបន្ថែមពីប្រភពផ្សេងៗ
- ព្យាយាមរំឭកឡើងវិញរាល់ការចងចាំដែលធ្លាប់មានពីមុនមក ប្រសិនបើអាចធ្វើបាន ព្រមទាំងធ្វើការពិចារណាឱ្យបានហ្មត់ចត់អំពីស្ថានភាពដែលនឹងត្រូវប្រឈម
- ត្រូវប្រាកដថាបរិយាកាសជុំវិញមានលក្ខណៈស្ងប់ស្ងាត់ល្អ និងមានសុវត្ថិភាពសម្រាប់ការសន្ទនា។

## ២. ការតម្រង់ទិស (នៅពេលសិស្សមកដល់)

- ស្វាគមន៍សិស្សដែលមកទទួលសេវាប្រឹក្សាយោបល់ ព្រមទាំងផ្តល់កន្លែងអង្គុយសមរម្យ
- ប្រាប់សិស្សអំពីការរក្សាការសម្ងាត់ក្នុងការប្រឹក្សាយោបល់នេះ
- គ្រូប្រឹក្សាតាមសាលារៀន អាចចែករំលែកព័ត៌មានទាំងនេះទៅអ្នកដទៃបាន ប្រសិនបើមានហានិភ័យដូចខាងក្រោម៖
    - ➢ មាននរណាម្នាក់បង្កឱ្យមានការរងទុក្ខដល់សិស្ស
    - ➢ សិស្សមានបំណងធ្វើឱ្យមានការរងទុក្ខដល់អ្នកដទៃ
    - ➢ សិស្សមានបំណងធ្វើឱ្យមានការរងទុក្ខដល់ខ្លួនឯង
- ជានិច្ចកាល ត្រូវលើកទឹកចិត្តសិស្សឱ្យរៀបរាប់ពីបញ្ហា (កង្វល់ ការលំបាក រឿងរ៉ាវផ្សេងៗ) ហើយត្រូវពន្យល់ហេតុផលប្រាប់ថា ហេតុអ្វីបានជាចាំបាច់ត្រូវធ្វើដូច្នេះ។ សុខុមាលភាពរបស់សិស្ស គឺអាស្រ័យទៅលើការទទួលខុសត្រូវរបស់មនុស្សចាស់ និងអ្នកអាណាព្យាបាល។
    - ➢ ប្រាប់សិស្សនូវរយៈពេលដែលត្រូវការ សម្រាប់ការប្រឹក្សាយោបល់នេះ
    - ➢ ស្នើសិស្សឱ្យនិយាយរៀបរាប់អំពីរឿងរ៉ាវ ឬបញ្ហារបស់គេ ដែលគេបានចងចាំតាមលទ្ធភាព
    - ➢ ប្រសិនបើមានពាក្យអ្វីចង់ជជែកជាមួយសិស្ស ត្រូវពន្យល់ខ្លឹមសារអ្វីខ្លះ និងហេតុអ្វីបានជាលើកយកមកជជែកគ្នានៅពេលនេះ?

## ៣. ការប្រឹក្សាយោបល់

### ❖ ការជជែកពិភាក្សា

- គ្រូប្រឹក្សាតាមសាលារៀន ត្រូវស្តាប់យោបល់ និងទស្សនៈផ្ទាល់ខ្លួនរបស់សិស្ស និងស្នើឱ្យគេនិយាយរៀបរាប់ពីរឿងរ៉ាវដែលបានកើតឡើងចំពោះខ្លួនគេ ហើយលើកទឹកចិត្តឱ្យគេនិយាយបន្តទៀត

- គ្រូប្រឹក្សាតាមសាលារៀន បង្កើតសំណួរបើកខ្លះៗ ដែលអាចជួយឱ្យខ្លួនបានយល់ពីបញ្ហារបស់សិស្ស កាន់តែច្បាស់។

ឧទាហរណ៍៖

➢ ចូរប្រាប់គ្រូបន្ថែមទៀតមើល ឬក៏ពន្យល់ឱ្យបានលម្អិតជាងនេះទៀតបានទេ?

➢ តើមានហេតុផលអ្វីដែរ បានជាអ្នកធ្វើអញ្ចឹង?

➢ ហេតុអ្វីបានជាគិតអញ្ចឹង?

➢ បានគំនិតហ្នឹងពីណា?

➢ វាបានកើតឡើងនៅពេលណា?

- និយាយប្រាប់ពីទស្សនៈ ឬគោលបំណងរបស់អ្នកដែលជាគ្រូប្រឹក្សាតាមសាលារៀន មានចេតនាជួយពិគ្រោះយោបល់ ដើម្បីស្វែងរកដំណោះស្រាយបញ្ហាទាំងនោះជាមួយគ្នាប្រកបដោយការគោរព។
- គ្រូប្រឹក្សាតាមសាលារៀន អាចសរសេរកំណត់ហេតុថ្មីៗ ប៉ុន្តែក៏ត្រូវឱ្យសិស្សអាននូវអ្វីដែលអ្នកបានសរសេរ
- ត្រូវចងចាំថាកាយវិការរបស់គ្រូប្រឹក្សាតាមសាលារៀន គឺសំខាន់ណាស់។ សូមកុំធ្វើពុតជាចាប់អារម្មណ៍ ប្រសិនបើអ្នកមិនចាប់អារម្មណ៍។ ត្រូវតែផ្តោតការយកចិត្តទុកដាក់ និងស្មោះត្រង់ជានិច្ចក្នុងការស្តាប់។
- ការពិភាក្សាសន្ទនាគួរត្រូវបានផ្តោតលើ៖

➢ ចែករំលែកព័ត៌មានអំពីអ្វីៗ (បញ្ហានានា) ដែលបានកើតឡើង

➢ ឆ្លុះបញ្ចាំងជាមួយគ្នានូវលទ្ធភាពផ្សេងៗក្នុងការរកដំណោះស្រាយបញ្ហា

➢ កំណត់គោលដៅច្បាស់លាស់

➢ ធ្វើផែនការជាមួយសិស្ស និងកំណត់ជំហានខ្លីៗ ដើម្បីឈានទៅរកការសម្រេចគោលដៅ

➢ គោលដៅត្រូវតែសម្រេចបាន។

### ៨. ការសន្និដ្ឋាន

- បូកសរុបនូវអ្វីៗដែលបានសន្ទនាគ្នានៅវគ្គប្រឹក្សាយោបល់ ជាពិសេសផែនការដែលបានរៀបចំ
- បង្ហាញកំណត់ហេតុដល់សិស្ស និងស្នើសិស្សឱ្យកែតម្រូវប្រសិនបើចាំបាច់ ឬមិនយល់ស្រប
- ធ្វើការណាត់ជួបលើកក្រោយទៀត អាចជួបគ្នានៅសប្តាហ៍ក្រោយ ខែក្រោយ ឬឆ្នាំក្រោយទៀត អាស្រ័យតាមស្ថានភាពរបស់សិស្ស រួមនឹងការយល់ដឹងរបស់គ្រូប្រឹក្សាអាជីពផងដែរ។

### ៩. ដំណាក់កាលបញ្ចប់

- នៅទីបញ្ចប់ សិស្សនឹងចាកចេញទៅ ក្រោយពីការទទួលសេវាប្រឹក្សាយោបល់ចប់សព្វគ្រប់
- ប៉ុន្តែមុននឹងគេចាកចេញទៅ គ្រូត្រូវសួរអារម្មណ៍របស់គេចំពោះសេវាផ្តល់ប្រឹក្សាយោបល់របស់គ្រូ និងស្ថានភាពខ្លួនផ្ទាល់របស់សិស្ស ថាតើគេអាចយល់ ឬទទួលយកបានប៉ុណ្ណា និងអាចយកទៅអនុវត្តដោយរបៀបណា?
- *អរគុណ* សិស្ស ដែលបានចំណាយពេលមកជួប និងជួបគ្នាលើកក្រោយទៀត។

គ្រូប្រឹក្សាតាមសាលារៀន ត្រូវឆ្លុះបញ្ចាំងអំពីសកម្មភាពផ្តល់ប្រឹក្សាយោបល់ និងអារម្មណ៍ផ្ទាល់ខ្លួន អ្វីដែលល្អ ឬអ្វីដែលត្រូវធ្វើលើកក្រោយទៀត ធ្វើដូចម្តេចដើម្បីឱ្យការផ្តល់ប្រឹក្សាលើកក្រោយៗ កាន់តែល្អប្រសើរជាងនេះ។ ការឆ្លុះចញ្ចាំង គឺសំខាន់ណាស់ ព្រោះវាជួយអភិវឌ្ឍជំនាញផ្តល់ប្រឹក្សាយោបល់ប្រកបដោយវិជ្ជាជីវៈ។ ការឆ្លុះបញ្ចាំងជាប្រចាំជាមួយគ្រូប្រឹក្សាតាមសាលារៀន ជាមួយគ្រូប្រឹក្សាតាមសាលារៀនមកពីសាលារៀនដទៃទៀត ក៏អាចជួយធ្វើឱ្យជំនាញរបស់គ្រូកាន់តែប្រសើរឡើងផងដែរ។

# ឧបសម្ព័ន្ធ៥ គំរូកំណត់ត្រាអំពីការផ្តល់សេវាប្រឹក្សាទល់មុខ

## ១. ព័ត៌មានអំពីគ្រូប្រឹក្សាតាមសាលារៀន

ឈ្មោះ.................................. ភេទ............ បុគ្គលិកអប់រំនៃ.......................................
លេខទូរសព្ទទាក់ទង.................................. កាលបរិច្ឆេទនៃការផ្តល់ប្រឹក្សា.........................

## ២. ព័ត៌មានអំពីអ្នកមកទទួលការប្រឹក្សា

ឈ្មោះ.................................. ភេទ............ អាយុ............... មុខងារ.........................
លេខទូរសព្ទផ្ទាល់ខ្លួន................................. ឈ្មោះអាណាព្យាបាល.................................
លេខទូរសព្ទអាណាព្យាបាល.................................... អាសយដ្ឋានបច្ចុប្បន្ន........................
.........................................................................................................

## ៣. ប្រធានបទនៃការផ្តល់ប្រឹក្សា

- ☐ ការរៀនយឺត
- ☐ បញ្ហាអវត្តមានច្រើន
- ☐ ការលើកកម្ពស់គុណភាពសិក្សាផ្ទាល់ខ្លួន
- ☐ ការប្រឈមនឹងការបោះបង់ការសិក្សា
- ☐ ការកំណត់ជម្រើសនៃការអប់រំបន្ត
- ☐ ការកំណត់ជម្រើសអាជីពនាពេលអនាគត
- ☐ ការត្រៀមខ្លួនស្នើសុំអាហារូបករណ៍ផ្សេងៗ
- ☐ ការត្រៀមខ្លួនចាប់ផ្តើមអាជីវកម្ម
- ☐ បញ្ហាហិង្សាគ្រួសារ
- ☐ បញ្ហាជីវភាព
- ☐ បញ្ហាស្នេហា និងយេនឌ័រ
- ☐ បញ្ហាផ្សេងៗ................................

## ៤. អន្តរាគមន៍របស់គ្រូប្រឹក្សាតាមសាលារៀន

- ☐ ការអនុវត្តតេស្តអំពីរបៀបរៀន
- ☐ ការអនុវត្តតេស្តពហុបញ្ញា
- ☐ ការអនុវត្តតេស្តសហគ្រិនភាព
- ☐ ការអនុវត្តតេស្ត RIASEC
- ☐ ការអនុវត្តកម្មវិធីត្រីវិស័យ
- ☐ ការអនុវត្តតេស្តផ្សេងៗ........................

## ៥. កិច្ចអន្តរាគមន៍បន្ទាន់

ទាក់ទងទៅកាន់...

- ☐ មាតាបិតា ឬអ្នកអាណាព្យាបាល
- ☐ គ្រូបង្រៀន ឬគណៈគ្រប់គ្រងសាលារៀន
- ☐ អាជ្ញាធរមូលដ្ឋាន
- ☐ ក្រុមហ៊ុន អាជីវកម្ម សហគ្រិន
- ☐ ផ្សេងៗ........................

### ៦. លទ្ធផលនៃការផ្តល់ប្រឹក្សា (រយៈពេល............)

| |
|---|
| ........................................................................................................ |
| ........................................................................................................ |
| ........................................................................................................ |
| ........................................................................................................ |

ថ្ងៃ........................ ខែ............ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

..................ថ្ងៃទី............ ខែ...............ឆ្នាំ២០២២

**គ្រូប្រឹក្សាតាមសាលារៀន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ០៥ អយក.សណន

**សេចក្តីណែនាំ**
**ស្តីពី**
**ការអនុវត្តកម្មវិធីត្រីវិស័យនៅតាមគ្រឹះស្ថានមធ្យមសិក្សា**

ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) បានបង្កើតកម្មវិធីផ្តល់ប្រឹក្សាតាមប្រព័ន្ធអេឡិចត្រូនិច "ត្រីវិស័យ" (TreyVisay) ក្នុងគោលបំណងឱ្យសិស្សស្វ័យវាយតម្លៃអំពីបុគ្គលិកលក្ខណៈ មុខរបរ និងឈ្វេងយល់អំពីព័ត៌មានគ្រឹះស្ថានសិក្សានិងទីផ្សារការងារ។

ដើម្បីឱ្យសិស្សអនុវត្តកម្មវិធីត្រីវិស័យ នៅតាមគ្រឹះស្ថានសិក្សាប្រកបដោយប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងគ្រឹះស្ថានសិក្សាទាំងអស់ដូចខាងក្រោម៖

**១. ភារកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត**

- ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រឹះស្ថានសិក្សាក្រោមឱវាទ ដើម្បីឱ្យសិស្សានុសិស្សចូលប្រើប្រាស់កម្មវិធីត្រីវិស័យប្រកបដោយប្រសិទ្ធភាព
- ណែនាំគ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទ រៀបចំផែនការអនុវត្តកម្មវិធីត្រីវិស័យ ឱ្យបានគ្រប់កម្រិតថ្នាក់
- ចូលរួមដោះស្រាយបញ្ហាប្រឈមផ្សេងៗ ជាមួយគ្រឹះស្ថានសិក្សា ក្នុងការប្រើប្រាស់កម្មវិធីត្រីវិស័យដោយស្មារតីទទួលខុសត្រូវខ្ពស់
- កៀរគរធនធាន និងដៃគូសហការ ដើម្បីគាំទ្រដំណើរការអនុវត្តកម្មវិធីត្រីវិស័យឱ្យមានប្រសិទ្ធភាព
- ពិនិត្យតាមដាន និងផ្តល់របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ អំពីការអនុវត្តកម្មវិធីត្រីវិស័យ នៅតាមគ្រឹះស្ថានសិក្សា ជូននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ។

**២. ភារកិច្ចរបស់គ្រឹះស្ថានសិក្សា**

- រៀបចំផែនការណែនាំការអនុវត្តកម្មវិធីត្រីវិស័យដល់សិស្សានុសិស្សគ្រប់កម្រិតថ្នាក់
- ចាត់តាំងឱ្យមានអ្នកទទួលខុសត្រូវក្នុងការណែនាំ និងប្រើប្រាស់កម្មវិធីត្រីវិស័យដល់សិស្ស
- ចូលរួមដោះបញ្ហាប្រឈមផ្សេងៗ ក្នុងការប្រើប្រាស់កម្មវិធីត្រីវិស័យ ដោយស្មារតីទទួលខុសត្រូវខ្ពស់
- កៀរគរធនធានដៃគូសហការ ដើម្បីគាំទ្រដំណើរការអនុវត្តកម្មវិធីត្រីវិស័យឱ្យមានប្រសិទ្ធភាព
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ អំពីការអនុវត្តកម្មវិធីត្រីវិស័យ ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

### ៣. តួនាទីរបស់គ្រូទទួលបន្ទុកអនុវត្តកម្មវិធីត្រីវិស័យ

- រៀបចំផែនការប្រចាំឆ្នាំ ស្តីពីការផ្សព្វផ្សាយ និងណែនាំការប្រើប្រាស់កម្មវិធីត្រីវិស័យដល់សិស្សគ្រប់កម្រិតថ្នាក់
- អនុវត្តការផ្សព្វផ្សាយ និងណែនាំការប្រើប្រាស់កម្មវិធីត្រីវិស័យ
- សម្របសម្រួលក្នុងដំណើរការប្រើប្រាស់កម្មវិធីត្រីវិស័យដល់សិស្ស
- ណែនាំសិស្ស អំពីរបៀបដំឡើងកម្មវិធីត្រីវិស័យក្នុងទូរសព្ទឆ្លាតវៃ ឬកុំព្យូទ័របន្ទះ (Tablet) ពីក្នុង App Store ឬ Play Store
